ខាងយោធាដើម្បីតស៊ូអាវុធ ហើយគាត់ខំសន្យាជាមួយខ្មែរថា “បើអាមេរិកពង្រីកសង្គ្រាម យើងនឹងឈានទៅតស៊ូដោយអាវុធតាមនោះដែរ”។ ឡេ យន់ មិនគិតគូរដល់ការ ដែលមានការរាតត្បាតនៅក្នុងស្រុកខ្មែរទាល់តែសោះ។ មេរៀនដែលវៀតណាមធ្លាប់បានប្រដៅខ្មែរទាំងប៉ុន្មាន ក៏បញ្ចោញវិញអស់ហើយ: ការតស៊ូរបស់ខ្មែរបេះមិនដាច់ ចេញពីការតស៊ូរបស់វៀតណាម និងលាវទេ។ វៀតណាមបានត្រូវរង់ចាំជ័យជម្នះបដិវត្តន៍ចិន ទើបទទួលបានជ័យជម្នះលើបារាំង ដូច្នេះខ្មែរក៏ត្រូវរង់ចាំជ័យជម្នះ វៀតណាមសិនដែរ ទើបបដិវត្តន៍របស់ខ្លួនទទួលជ័យជម្នះ។ ក្រោយពីវៀតណាមទទួលបានសេរីភាព សេរីភាពក៏មកដល់កម្ពុជាជាស្វ័យប្រវត្តិ។ ការដែលបក្សខ្មែរនិយាយសង្កត់អំពី “ស្វ័យភាពដូចជាហួសហេតុបន្តិចហើយ”។ ហេតុផលរបស់ ឡេ យន់ គឺទំនាស់សំខាន់ជាងគេនៅក្នុងសកលលោក គឺទំនាស់រវាងសង្គមនិយម និងមូលធននិយម មិនមែនទំនាស់រវាងប្រជាជនដែលត្រូវគេជិះជាន់ និងចក្រពត្តិនិយម ដូចខ្មែរនិយាយនោះទេ។ ហើយក្នុងសភាពការណ៍នេះ អ្វីដែលសំខាន់ គឺសាមគ្គីភាពអន្តរជាតិ។

ចំពោះ ស តាំងពីឆ្នាំ១៩៥៥ ដែលគេបានធ្វើការណែនាំដល់បក្សខ្មែរក្រោយពីកិច្ចព្រមព្រៀងហ្សឺណែវ នយោបាយរបស់អ្នកដឹកនាំវៀតណាមអត់មានអ្វីប្រែប្រួលបន្តិចសោះ។ គេរក្សាសិទ្ធិធ្វើការណែនាំមកខ្មែរ ប៉ុន្តែខ្មែរវិញ អត់មានសិទ្ធិនិយាយអ្វីបានទេ។ នេះហើយបានចេញជាពាក្យបៀបជាការបញ្ជាជាចុងក្រោយរបស់ ឡេ យន់ ហាមថា: “យ៉ាងហោចណាស់នៅពេលនេះ កុំប៉ះពាល់ដល់សម្តេច សីហនុ ទាល់តែសោះ”។[១០៧]

ហើយដោយ ឡេ យន់ ចង់ឲ្យ ស ឃើញពលីកម្មដែលវៀតណាមបានធ្វើ ដើម្បីជួយដល់ការតស៊ូរបស់ខ្មែរ ឡេ យន់ក៏ស្នើឲ្យ ស ទៅមើលឯកសារ

[១០៧] ហ្វីលិព ហ្សត “ប៉ុល ពត...” ទំព័រ១៥៧ (អ្នកនិពន្ធយោងទៅសំភាសន៍របស់លោកសាឡុត ស ជាមួយអ្នកកាសែតចិនឈ្មោះកាយ ស៊ីម៉ឺ នៅខែឧសភា ឆ្នាំ១៩៨២)



ដែលវៀតណាមបានរក្សាទុកក្នុងសំណុំឯកសាររបស់វៀតណាម។ ស ចំណាយពេលអស់ច្រើនថ្ងៃ ដើម្បីអានឯកសារទាំងនោះយ៉ាងល្អិតល្អន់ ហើយក៏ទាញសេចក្តីសន្និដ្ឋានរបស់គាត់ថា:

“ខ្ញុំបានឃើញថា តាំងពីឆ្នាំ១៩៣០.... ដល់ឆ្នាំ១៩៦៥ ឯកសារទាំងអស់របស់បក្សកុម្មុយនីស្តវៀតណាម បាននិយាយពីបក្សបដិវត្តប្រជាជនកម្ពុជា និងលាវ ដូចជាមែកធាងរបស់បក្សវៀតណាម...។ បក្សទាំងពីរអនុវត្តច្បាប់មាគ៌ានយោបាយ និងយុទ្ធសាស្ត្ររបស់បក្សវៀតណាម...។ មុននឹងខ្ញុំបានឃើញឯកសារទាំងអស់នេះដោយផ្ទាល់ខ្លួនខ្ញុំ ខ្ញុំជឿទុកចិត្តលើវៀតណាម។ ប៉ុន្តែក្រោយពីបានអានឯកសារទាំងអស់នោះទៅ ខ្ញុំឈប់ជឿលើគេហើយ។ ខ្ញុំឃើញថា គេបានចាត់តាំងអង្គការបក្សនៅក្នុងស្រុកយើង ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រតែមួយ គឺសហព័ន្ធឥណ្ឌូចិន។ គេបានបង្កើតបក្សតែមួយ ដើម្បីតំណាងឲ្យទឹកដីដែលបញ្ចូលគ្នាតែមួយ”។[១០៨]

ការពិតទស្សនកិច្ចឆ្នាំ១៩៦៥ ជាផ្លូវបត់មួយ។ រហូតមកដល់ពេលនេះពិតមែនហើយ ខ្មែរធុញទ្រាន់នឹងវៀតណាម ដែលតាំងខ្លួនជាឪរបស់ខ្មែរខ្លាំងណាស់ តែគេមិនដែលនឹកសង្ស័យសូម្បីតែបន្តិច ក៏គ្មានសោះចំពោះទិសដៅរួមរបស់បក្សទាំងពីរ។ ក្រោយពីបានពិភាក្សាគ្នានៅហាណូយ ស បានឈានដល់សេចក្តីសន្និដ្ឋានថា ផលប្រយោជន៍វៀតណាមមិនដូចផលប្រយោជន៍ខ្មែរទេ នេះមិននិយាយដល់ពាក្យថាផ្ទុយគ្នាផង។ ប៉ុន្តែចំពោះមុខនេះ មិនទាន់លេចចេញជាចំហរទេ ហើយទាំងសងខាងនៅតែរក្សាភាពដូចជា គេទាំងពីរនាក់ជាមិត្តភក្តិស្លាប់រស់ជាមួយគ្នា។[១០៩]

[១០៨] ហ្វីលិព ហ្សត “ប៉ុល ពត...” ទំព័រ១៥៧ (អ្នកនិពន្ធយោងទៅតាមសេចក្តីសំភាសន៍ជាមួយអ្នកកាសែតចិន ឈ្មោះ កាយ ស៊ីម៉ឺ)

[១០៩] ហ្វីលិព ហ្សត “ប៉ុល ពត...” ទំព័រ១៥៩

នៅក្នុងពេលដែល ស ស្នាក់នៅវៀតណាម ស បានប្រាប់ទៅម្ចាស់ផ្ទះថា គេចង់ទៅចិន។ អស់រយៈពេលជាច្រើនខែទើប ចម្លើយរបស់ប៉េកាំងមកដល់។ ស បានស្នាក់នៅចិន១ខែនៅប៉េកាំង។ ស បានជួបនឹងបរិយាកាសគួរឲ្យរំភើបចិត្ត ក្រោយពីការលំបាកចិត្តដែលបានកើតមាននៅហាណូយ។ កូនសៀវភៅក្រហមរបស់តាម៉ៅ ទើបតែបានបោះពុម្ពសាជាថ្មីឡើងវិញ ហើយជាពិសេសសុន្ទរៈកថា ដែលប្រកបទៅដោយអត្ថន័យធំធេងរបស់រដ្ឋមន្ត្រីការពារប្រទេសលិនពាវក្រោមចំណងជើងថា "ជយោ!ជ័យជម្នះនៃសង្គ្រាមប្រជាជន" បានផ្តល់ការគាំទ្រដល់គោលជំហររបស់បក្សខ្មែរស្ទើរគ្រប់ចំណុច។

ជាជម្រៅ ចិនក៏មិនខុសពីវៀតណាមប៉ុន្មានដែរ គឺគេព្រួយពីការកើតមានការតស៊ូអាវុធនៅកម្ពុជា ហើយហេតុផលក៏ដូចគ្នា។ កិច្ចសហការជាមួយសម្តេច សីហនុ មានសារៈសំខាន់ជាអាយុជីវិតដើម្បីបន្តសង្គ្រាមខាងត្បូង។ ប៉ុន្តែដែលខុសពីវៀតណាម គឺប៉េកាំង គោរពឯករាជ្យរបស់បក្សជាបងប្អូន។ ចិនកំពុងស្វែងរកសម្ព័ន្ធមិត្តថ្មីក្នុងជម្លោះរបស់គេជាមួយ សហភាពសូវៀត ហើយទោះបីគេមានការទាក់ទងជាភាគរៈជាមួយវៀតណាមក៏ដោយ ការលេចចេញបក្សខ្មែរមួយដែលឯករាជ ហើយមានមនោគមន៍វិជ្ជាប្រហាក់ប្រហែលគេដែរ ជាទីបញ្ចប់ទៅ អាចទូទាត់បានជាមួយនឹងការបាត់បង់ឥណ្ឌូចិន ដែលនៅក្រោមបង្កាប់របស់វៀតណាម។ ចំពោះសាឡុតសវិញ ការរស់នៅ១ខែនៅចិន ជាដំណាក់កាលមួយនៃការចាប់ផ្តើមសម្ព័ន្ធភាពថ្មីមួយទៅហើយ ហើយគាត់ក៏អាចត្រូវបានលើកទឹកចិត្តខ្លាំងដែរ។

**ឈ-ចុងឆ្នាំ១៩៦៦ ផ្លូវបត់មួយធំទៀត ឆ្ពោះទៅរកឯករាជ្យពេញលេញពីវៀតណាម**

ត្រឡប់មកដល់មន្ទីរ១០០វិញភ្លាមនៅចុងឆ្នាំ១៩៦៦ លោកសាឡុតសក៏កោះប្រជុំមួយ ដើម្បីសម្រេចពីយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្សសម្រាប់ឆ្នាំក្រោយ[១១០]។ ការប្រជុំត្រូវដាច់ជាញឹកញាប់ដោយសារតែយន្តហោះ

[១១០] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៥៨



របស់ "សត្រូវ" ប្រហែលជាយន្តហោះរបស់អាមេរិក ដែលហោះយាមតាមព្រំប្រទល់។ ការតម្លើងថ្នាក់សង្គ្រាមនៅវៀតណាម ព្រឹត្តិការណ៍នៅឥណ្ឌូនេស៊ី និង សភាពការណ៍វិវត្តន៍នៅក្នុងប្រទេសកម្ពុជា ជារបៀបវារៈសំខាន់ៗ។ ដំណឹងនៃការសម្លាប់រង្គាលនៅឥណ្ឌូនេស៊ី-ចន្លោះខែតុលា ១៩៦៥ និងមីនា ១៩៦៦ កើតមានព្រឹត្តិការណ៍មួយគួរឲ្យរន្ធត់ដែល លោកប្រធានាធិបតីស៊ូការណូត្រូវបានគេចាប់ ហើយសមាជិកបក្សកុម្មុយនីស្ត ឥណ្ឌូនេស៊ី និងសមានជនជាងបីសែននាក់ត្រូវគេសម្លាប់ និងចាប់ដាក់គុក។ បក្សកុម្មុយនីស្តឥណ្ឌូណេស៊ី ត្រូវរលាយ -ធ្វើឲ្យលោកសាឡុតសព្រួយចិត្តខ្លាំង។ បើប្រសិនជាកងទ័ពដែល "ស្និទ្ធជាមួយអាមេរិករបស់លោកលន់ នល់" សម្រេចធ្វើដូចនៅឥណ្ឌូនេស៊ីនេះ សម្តេចនរោត្តម សីហនុ មិនអាចការពារនរណាបានទេ។ ប៉ុន្តែវៀតណាមនៅតែទទូចឲ្យខ្មែរបន្តសម្ព័ន្ធភាពជាមួយសម្តេច។ ដូច្នេះគឺហាក់ដូចជាវៀតណាមបញ្ជាឲ្យខ្មែរធ្វើដំណើរមួយឈានទៅសម្លាប់ខ្លួនឯង។ ឯវៀតណាមវិញក៏មិនអាចមកសង្គ្រោះខ្មែរបានដែរ។ ការប្រជុំប្រព្រឹត្តទៅអស់រយៈពេល២អាទិត្យ។[១១១] អង្គប្រជុំបានធ្វើសេចក្តីសម្រេច៣ខ៖

**ខទី១**-បក្សដូរឈ្មោះពីបក្សពលករ ទៅជាបក្សកុម្មុយនីស្តកម្ពុជា។ តាមយោបល់ខ្ញុំមានតែ ស ម្នាក់ឯងទេ ដែលយល់ហេតុផលនៃការផ្លាស់ប្តូរឈ្មោះនេះច្បាស់ជាងគេ។ គឺជាការប្រកាសឯករាជ្យពីវៀតណាម។ ប៉ុន្តែការប្តូរឈ្មោះនេះនៅរក្សាជាការសម្ងាត់នៅឡើយទេ។ សមាជិកផ្សេងទៀតនៃបក្សអត់បានដឹងទេ។ វៀតណាមក៏មិនដឹងដែរ។

**ខទី២**-គឺបក្សសម្រេចចេញពីមន្ទីរ១០០ ដើម្បីទៅតាំងនៅកន្លែងមួយដាច់ស្រយាលក្នុងខេត្តរតនៈគិរី។ ហេតុផលដែលគេជំរាបវៀតណាម គឺថា ការពង្រីកសង្គ្រាមនៅវៀតណាមខាងត្បូង បានបង្ខំគេឲ្យរកកន្លែងមួយដែលធានាជាងនេះ។ ឯការពិត គឺដើម្បីគេចឲ្យឆ្ងាយពីការត្រួតត្រារបស់

[១១១] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៥៨

វៀតណាម។ នៅរតនៈគីរី ខ្មែរមានមូលដ្ឋានមួយរបស់ខ្លួន ដែលឆ្ងាយពីក្អែកប្រមុះរបស់វៀតណាម ហើយដែលខុសពីមន្ទីរ១០០ គឺនៅក្នុងទឹកដីកម្ពុជា។

**ខទី៣**-ដែលជាការសម្រេចសំខាន់ជាងគេ គឺភូមិភាគនីមួយៗត្រូវត្រៀមរៀបចំចូលក្នុងការតស៊ូអាវុធ។

ប៉ុន្តែការសម្រេចនេះ ក៏បានសរសេរឡើងនៅក្នុងពាក្យដែលប្រយ័ត្នប្រយែងនៅឡើយ។ ម៉្យាងខាងខ្មែរក៏មិនទាន់ហានធ្វើអ្វីដែលនាំឲ្យវៀតណាមខឹងសម្បារនៅឡើយ ហើយម៉្យាងទៀតខាងផ្ទៃក្នុងខ្មែរក៏នៅមិនទាន់ឯកភាពគ្នាទាំងស្រុងនៅឡើយ។ សេចក្ដីសម្រេចណែនាំឲ្យខិតខំពង្រឹងពង្រីកផ្នែកសម្ងាត់របស់បក្សនៅទីក្រុងឲ្យកាន់តែសកម្មប្រយុទ្ធខាងនយោបាយ ហើយក្នុងការ "ប្រើហឹង្សានយោបាយ" បើឱកាសអាចធ្វើទៅបាន ត្រូវហានប្រើ "អាវុធ"។ ក្នុងការសម្រេចទាំងអស់នេះ មិនទាន់មានអ្វីដែលវៀតណាមមើលទៅថា មិនអាចទទួលបាននោះទេ។ ប៉ុន្តែបើគេមើលតាមចន្លោះបន្ទាត់វិញ ការសម្រេចនេះមានលំនាំជាការចាប់ផ្ដើមសង្គ្រាមផ្ទៃក្នុងទៅហើយ ដែលមានន័យថាជាការទាត់ចោលហេតុផលទាំងអស់ដែល ឡេ យន់ បានលើកឡើង ហើយបានសុំកុំអាលឲ្យខ្មែរធ្វើអ្វីដែលវៀតណាម មិនទាន់បានយល់ព្រមជាមុននោះ។

នៅផ្នែកខាងផ្ទៃក្នុងវិញ មួយរយៈមកហើយដែល វន វេត និងសូ ភឹម មានការព្រួយបារម្ភពីយុទ្ធសាស្ត្រតស៊ូអាវុធនោះ។ វន វេត បានសរសេរថា "ជាជំហរខ្ញុំ ខ្ញុំប្រឆាំងនឹងការតស៊ូអាវុធនៅជនបទ។ ទី១ ជាជំហរផ្ទាល់ខ្លួនរបស់ខ្ញុំៈ ខ្ញុំយល់ថា មិនអាចទៅរួចទេ... នៅពាក់កណ្ដាលឆ្នាំ១៩៦៦ បងភឹម បានមកពីមូលដ្ឋានរបស់គាត់ មកនៅផ្ទះ សែ ពេលនោះគាត់ជានារសារ... បងភឹម ចង់ទៅលេងសៀមរាប ដើម្បីមើលអង្គរ ហើយត្រឡប់មកវិញតាមបាត់ដំបង ខ្ញុំជូនដំណើរគាត់... បងភឹម បានលើកបញ្ហាតស៊ូអាវុធជាមួយខ្ញុំ។ គាត់ថា យើងត្រូវតែប្រឆាំង។ ប្រជាជនមិនចង់បង្ហូរឈាមទេ... ក្នុងមូលដ្ឋានបូព៌ា នឹងមានការលំបាកមែនទែន បើប្រសិនជាមានការតស៊ូអាវុធ...ខ្ញុំ (វន



វេត) ឆ្លើយថា មិនបានការអ្វីទាំងអស់... យើងមានតែបាតដៃទទេយ៉ាងនេះ សត្រូវនឹងកំទេចយើងមុន ហើយយើងពុំអាចងើបឡើងវិញបានទេ។[១១២]

ប៉ុន្តែការព្រួយបារម្ភទាំងអស់នេះ ក៏រសាត់ទៅវិញយ៉ាងឆាប់រហ័ស។[១១៣] ការរាតត្បាតរបស់រដ្ឋាភិបាលប្រឆាំងនឹងពួកឆ្វេង ដែលបានចាប់ផ្ដើមកើនតាំងពីឆ្នាំ១៩៦៤ បានឡើងដល់កំរិតដែល "ជាទូទៅ ផ្នែកយោធា និងផ្នែកសន្តិសុខ គេសម្រេចធ្វើអ្វីៗបានដោយឯករាជ្យហើយ ហើយពេលខ្លះដោយមានការយល់ស្របដោយស្ងាត់ៗពីសម្ដេចផង។ គឺចាប់ពីពេលនោះមកហើយដែលតាមគ្រប់ប្រកពទាំងអស់ ការរាតត្បាតដោយ "ឥតត្រាប្រណី" បានក្លាយទៅជាការធម្មតាទៅហើយ"។[១១៤]

នៅរវាងចុងឆ្នាំ១៩៦៦ អ្វីៗទាំងអស់ដែលគណៈកម្មាធិការមជ្ឈិម ខែតុលា ១៩៦៤ បាននិយាយទុកមុននោះ ពិសេស គឺការឃុបឃិតរបស់សហរដ្ឋអាមេរិកគាំទ្រលោកលន់ នល់... ប្រឆាំងសម្ដេច សីហនុ "គឺលេចឡើងកាន់តែច្បាស់ ការសម្រេចពេលនោះ គឺមិនត្រូវពឹងលើសម្ពន្ធភាពរវាងសម្ដេច និង វៀតណាម -ចាំបាច់ជាអាយុជីវិតពឹងលើកម្លាំងរបស់ខ្លួនឯង - រួមផ្សំការតស៊ូអាវុធ និងការតស៊ូនយោបាយ... ត្រូវបានបញ្ជាក់ថាត្រឹមត្រូវទាំងអស់។

អ្នកសង្កេតការសឹងតែទាំងអស់គ្នាមើលឃើញថា សភាថ្មីដែលចេញមកពីការបោះឆ្នោតថ្ងៃ១១ ខែកញ្ញា គឺជាសភា "ខាងស្ដាំ" មានសុទ្ធតែនាម៉ឺនមន្ត្រី និងអ្នកជំនួញ។ ហើយប្រហែលជាព្រះអង្គចង់គេចមិនព្រមព្រោះព្រំ

---

[១១២] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៣០ (អ្នកនិពន្ធបានយោងទៅសេចក្ដីសារភាពរបស់ វន វេត នៅឆ្នាំ១៩៧៨)

[១១៣] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៣០

[១១៤] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៣០-២៣១ (អ្នកនិពន្ធដែលគូសបញ្ជាក់)

ឲ្យរដ្ឋាភិបាល ដែលព្រះអង្គច្បាស់ជាមិនពេញចិត្តនោះ ព្រះអង្គមិនចង្អុលនាយករដ្ឋមន្ត្រីនិងសមាជិករដ្ឋាភិបាលខ្លួនព្រះអង្គ ដូចដែលព្រះអង្គធ្លាប់ធ្វើពីមុនមកនោះទេ។ ព្រះអង្គសូមឲ្យសភាជ្រើសរើសខ្លួនឯង។ នៅថ្ងៃ១៨ តុលា ដូចដែលទាំងអស់គ្នាប៉ាន់ស្មានជាមុន សភាក៏តែងតាំងលោកលន់ នល់ ជានាយករដ្ឋមន្ត្រី ហើយមួយអាទិត្យក្រោយមក ក៏លោកលន់ នល់ តែងតាំងរដ្ឋាភិបាលខាងស្តាំ។ គឺជាលើកទីមួយ ហើយដែលរដ្ឋាភិបាលមិនត្រូវបានប្រមុខរដ្ឋតែងតាំង។ ទូតបារាំងនៅភ្នំពេញក៏បានធ្វើសារទៅប៉ារីសថា "មានតែរឿងមួយទេ ដែលសមាជិករដ្ឋាភិបាលយល់ស្របជាមួយគ្នា គឺទាំងអស់គ្នាមិនស្មោះត្រង់ចំពោះសម្តេច"។[១១៥]

ឯចំពោះសម្តេចវិញ ការលេចចេញមកនូវរដ្ឋាភិបាលមួយ ដែលឯករាជពីព្រះអង្គរបៀបនេះ ជាបញ្ហាមួយដែលលោកត្រូវតែដោះស្រាយឲ្យបានស្រួល។ លោកបានខិតខំដោយលំបាក ដើម្បីកំរិតអំណាចរបស់នាយករដ្ឋមន្ត្រីថ្មី។ ប៉ុន្តែលោកបែរទៅជាអស់ជំនឿលើខ្លួនលោក ហើយក៏បែរមកថតកុនវិញ។ តាំងពីនោះមក កុនរបស់លោក ក៏ដូចជានយោបាយរបស់លោកមិនសូវទទួលបានជោគជ័យទេ។ ការពិត គឺចាប់ពីពេលនេះទៅហើយដែលសម្តេចត្រូវកម្លាំងខាងស្តាំហ៊ុមព័ទ្ធ។

ចាប់ពីដើមខែមករា ឆ្នាំ១៩៦៧ សម្តេចក៏យាងចេញពីស្រុកខ្មែរចំនួន ២ខែ ដើម្បីទៅព្យាបាលជម្ងឺធាត់របស់លោកនៅស្រុកបារាំង។ លោក បែន គៀរណាន់បានសរសេរដូចតទៅ: "សឹងតែច្បាស់ណាស់ដោយមានការយល់ស្របពីសម្តេចផង លោកលន់ នល់ ហាក់ដូចជាបានជ្រើសរើសពេលវេលានេះ ដើម្បីបង្កើនការវាតត្បាត ប្រហែលជាក្នុងទិសដៅជ្រមុជផែនការតស៊ូដោយអាវុធរបស់បក្សកុម្មុយនីស្តកម្ពុជាទៅក្នុងភក់"។[១១៦] ព្រមជាមួយនេះ ឱកាសក៏ហាក់ដូចជាមាននៅនឹងមុខគាត់ស្រាប់។ ពីឆ្នាំមុន៤០%នៃស្រូវ ដែលច្រូតបានទូទាំងប្រទេស ត្រូវបានរត់ពន្ធសម្រាប់បំរើវៀតកុង ធ្វើឲ្យបាត់ប្រាក់ចំណូលរបស់រដ្ឋប្រហែល២/៣។ បញ្ហាគឺនៅត្រង់ពួកកុម្មុយនីស្តវៀតណាមហានឲ្យថ្លៃជាងរដ្ឋខ្មែរ។ ដូច្នេះដើម្បីប្រមូលស្រូវជូនរដ្ឋបានតាមតម្លៃដែលរដ្ឋកំណត់ លុះត្រាតែប្រើកំលាំង។ ដូច្នេះសម្តេចក៏យល់ស្របតាមផែនការនាយករដ្ឋមន្ត្រីថ្មីបញ្ជូន "ក្រុមសកម្មភាព" ដោយមានយោធាអមផងឲ្យទៅជនបទ។

ចំពោះ ស និងសហការីរបស់គាត់វិញ លទ្ធផលនៃការបោះឆ្នោតក្តី លោកលន់ នល់ ឡើងធ្វើនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលមួយដែលមិនខ្វាចញញើតសម្តេចក្តី មិនមានអ្វីគួរឲ្យគាត់ភ្ញាល់ទេ។ នេះគឺជាដំណាក់កាលមួយនៃការ "រៀបចំក្បត់" ដែលគាត់បានមើលឃើញយូរមកហើយ ហើយដែលគាត់ និង គណៈកម្មាធិការមជ្ឈឹមបានខិតខំរកវិធីដើម្បីទប់ទល់តាំងពីឆ្នាំ១៩៦២ម៉្លេះ។ ឯរឿងទាំងអស់នេះ ទោះបីសម្តេចលោកជ្រាបក្តី មិនជ្រាបក្តី មួយផ្នែកធំ គឺមកពីលោកដែរ។ ជាង១ទសវត្សរ៍មកហើយ ក្នុងឋានៈជារដ្ឋមន្ត្រីការពារប្រទេសលោក លន់ នល់ បានទទួលភារកិច្ចធ្វើការវាតត្បាតប្រឆាំងកុម្មុយនីស្ត។ ជាង១ទសវត្សរ៍មកហើយដែរ ការរឹតចំណងមិត្តភាពជាមួយប្រទេសសង្គម និយមខាងក្រៅប្រទេស បានដំណើរការទៅដោយសម្តេចផ្អែកលើកម្លាំងខាងស្តាំកាន់តែខ្លាំងឡើងៗ ដើម្បីវាតត្បាតកាន់តែខ្លាំងឡើងៗលើកម្លាំងខាងឆ្វេងនៅក្នុងប្រទេស។ បញ្ជីអ្នក៣៤នាក់ដែលលោកលន់ នល់រៀបចំឡើងក្នុងឆ្នាំ១៩៦៣ ក្រោយពីសម្តេច បានច្រៀងសរសើរប្រទេសចិនកុម្មុយនីស្តអស់ជាងមួយអាទិត្យ គឺគ្រាន់តែជាចំណែកមួយនៃអ្វីដែលគេអាចមើលឃើញខ្លះតែប៉ុណ្ណោះទេ។ ឯផ្នែកដែលគេមិនបានមើលឃើញមានច្រើនជាងនេះ។ យូរៗទៅនយោបាយក្រៅប្រទេស ដែលទាក់ទងជាមួយប្រទេសសង្គមនិយមរួមផ្សំជាមួយនយោបាយក្នុងប្រទេសដែលផ្អែកលើកម្លាំងខាងស្តាំ ដើម្បីវាតត្បាតកម្លាំងខាងឆ្វេងរបៀបនេះ នឹងធ្វើឲ្យកម្លាំងខាងស្តាំដែលស្និទ្ធជាមួយសហរដ្ឋអាមេរិក កាន់តែរីកធំធាត់ឡើងៗ

[១១៥] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៦២-១៦៣

[១១៦] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៤១

រហូតដល់ថ្ងៃណាមួយវានឹងហ៊ុមព័ទ្ធសម្តេចខ្លួនព្រះអង្គជៀសពុំផុតទេ។ ឯអំណាចរបស់សម្តេចវិញកាន់តែត្រូវរេចរឹលទៅៗ។ ឧទាហរណ៍ដល់រវាងដើមឆ្នាំ១៩៦៦ កម្លាំងខាងស្តាំមានកម្លាំងខ្លួនវា ដើម្បីហានទិទៀនដោយចំៗផង ដោយបញ្ចិតបញ្ចៀងផង អំពីការដែលសម្តេចមានវិធីបន្ទឹមបន្ទំបង្ហាញឲ្យគេឃើញអំពើផ្តាច់ការរបស់លោក ទៅជាប្រជាធិតេយ្យទៅវិញ ហើយនឹងទិទៀនរាជវង្សានុវង្សអំពីអំពើពុករលួយ..។ នេះហើយដែលនាំឲ្យលោកឈប់ជ្រើសរើសបេក្ខជនសង្គមរាស្ត្រនិយម សម្រាប់ឈរឈ្មោះបោះឆ្នោតឆ្នាំ១៩៦៦។ នេះហើយដែលពួកលោកលន់ នល់រៀបចំដាក់បេក្ខជនរបស់គេវិញ។ នៅពេលនោះមានអ្នកទូតខ្លះសរសេរថា បរិយាកាសនយោបាយដូចជាអាប់អួរ។[១១៧]

សភាពការណ៍មកដល់នេះហើយ ពិបាកនឹងត្រឡប់ថយក្រោយវិញណាស់។ ពួកខាងស្តាំគេអាចធ្វើអ្វីៗដោយឯករាជ្យពីសម្តេចបានហើយ ហើយពេលខ្លះគេអាចបង្កបង្កើតលក្ខណៈសម្បត្តិផ្សេងៗ ដើម្បីឲ្យសម្តេចយល់ស្របតាមគេផងក៏បាន។ ឡែ យន់ ដោយសំអាងខ្លួនថាជាបក្សធំ មិនព្រមស្តាប់ការពន្យល់របស់លោកសាឡុតស អំពីសភាពការណ៍នេះសោះ។ ដូច្នេះបក្សខ្មែរមិនអាចដើរតាមផ្លូវដែលរាមច្បងវៀតណាមចង្អុលប្រាប់ទាំងទទឹងទិសយ៉ាងនេះទៀតទេ ពីព្រោះបើដើរតាមផ្លូវនេះតទៅទៀត គឺវាហាក់ដូចជាឈានទៅរកការសម្លាប់ខ្លួនឯង។ ដូចបានរៀបរាប់មកហើយបក្សខ្មែរក៏ឈានមួយជំហានទៀតតាមផ្លូវរបស់ខ្លួនដោយឡែកគឺគេណែនាំឲ្យភូមិភាគនីមួយៗត្រៀមរៀបចំ "តស៊ូអាវុធ"។

### ញ-ត្រឡប់មកពិនិត្យឫសគល់នៃការបះបោររបស់កសិករនៅសំឡូត

ពិតមែនហើយ ការដែលរដ្ឋទិញស្រូវដោយឲ្យតម្លៃថោកជាងនៅតាមផ្សារ ជាកត្តាមួយដែលធ្វើឲ្យបរិយាកាសនយោបាយរួមតឹងតែង ប៉ុន្តែនេះមិនមែនជាឫសគល់នៃការបះបោររបស់ប្រជាកសិករនៅសំឡូតដូចជា អ្នកស្រាវជ្រាវផ្សេងៗ បានសន្និដ្ឋាននោះទេ។ ពីព្រោះកសិករនៅកម្ពុជាមិនមែនជាអ្នកលក់ស្រូវរបស់ខ្លួនទេ គឺពួកដែលធ្វើការបុលបណ្តាក់យកការប្រាក់ខ្ពស់ និងពួកស្ថានកណ្តាលទេដែលជាអ្នកាន់កាប់ផ្សារលក់ស្រូវ។

ឫសគល់នៃការបះបោរនៃកសិករនៅសំឡូត គឺការរាតត្បាតរបស់លោកលន់ នល់។ នៅពេលក្រោយបន្តិចមក សម្តេចបានមានបន្ទូលអំពីកម្មវិធីរបស់លោកលន់ នល់នេះដូចតទៅ "ការប្រមូលស្រូវបានធ្វើឡើងដោយបង់ថ្លៃថោក ដូច្នេះឈ្មួញស្ថានកណ្តាលត្រូវកំចាត់អស់"។ អ្វីដែលគួរឲ្យកត់សម្គាល់នៅក្នុងកម្មវិធីនេះ គឺសម្តេចភ្ជាប់កម្មវិធីនេះទៅការប្រឆាំងខាងឆ្វេង។ "កម្មវិធី (វិទ្ធង្សនា) និងបំផ្ទិចបំផ្លាញត្រូវជួបប្រទះនឹងការលំបាកពេលដែលសហជីវិនលោកលន់ នល់បង្កើតគណៈកម្មាធិការសកម្មភាព ដើម្បីប្រមូលស្រូវនៅតាមស្រុក ឃុំ និងភូមិ គណៈកម្មាធិការសកម្មភាព ដែលតំណាងឲ្យសង្គមអ្នកជាតិនិយម ហើយធ្វើឲ្យសាខាពួកក្រុម "ប្រជាជន" ពិបាករស់នៅ។ រហូតមកដល់ពេលនេះគ្មានអ្នកណារំខានដល់គេសោះ ហើយគេធ្វើសកម្មភាពដែលគ្មានអ្នកណាផ្តន្ទាទោសគេសោះ។[១១៨]

ការពិតដល់ខែមករា-កុម្ភៈ ដែលកម្មវិធីប្រមូលស្រូវ ចាប់ផ្តើម ស្រូវបានប្រូតកាត់ហើយ ធ្លាក់ទៅក្នុងកណ្តាប់ដៃពួកបុលបណ្តាក់ភាគច្រើនអស់។ មានន័យថា បើលោកលន់ នល់ចង់ប្រមូលស្រូវមែននោះ លោក មិនបាច់ចាត់តាំង "គណៈកម្មាធិការសកម្មភាព" នៅតាមស្រុក ឃុំ និងភូមិទេ លោកត្រូវបែរទៅមើលតាមខេត្ត និងទីប្រជុំជនសំខាន់ៗឯណោះវិញ"។

តាមការពិត ខ្ញុំបានឮគេនិយាយពី "គណៈកម្មាធិការសកម្មភាព" តាំងពីយូរឆ្នាំណាស់មកហើយ។ លោកលន់ នល់បានចាត់តាំងគណៈកម្មាធិការ

---

[១១៧] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៦៣

[១១៨] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៥២ (អ្នកនិពន្ធសំអាងទៅលើសុន្ទរៈកថារបស់សម្តេច នៅភ្នំពេញខែមីនា ១៩៦៧)

នេះ នៅតាមជនបទទូទាំងប្រទេសដោយសម្ដេចមិនបានជ្រាបផងទេ។ វាជាឧបករណ៍សម្រាប់វាតត្បាតពួកកុម្មុយនីស្ដផង សម្រាប់បំរើការលោកលន់ខាងនយោបាយរបស់លោកផ្ទាល់ខ្លួនផង។ ឧទាហរណ៍ លទ្ធផលនៃការបោះឆ្នោតឆ្នាំ១៩៦៦ មួយភាគធំជាលទ្ធផលនៃសកម្មភាពរបស់ "គណៈកម្មាធិការ" នេះ។

នៅក្នុងអំឡុងឆ្នាំ១៩៥០ សំឡូតជាមូលដ្ឋានមួយរឹងមាំនៃសង្គ្រាម ឈ្លបប្រឆាំងនឹងបារាំង។ ដូច្នេះមួយរយៈយូរមកហើយ ក្រោយហ្សឺណែវ ប្រជាជននៅកន្លែងនេះ ត្រូវគេធ្វើទុក្ខធ្វើបាប និងរំលោភគ្រប់បែបយ៉ាងទាំងអស់។ ឥឡូវនេះបន្ថែមពីលើការធ្វើទុក្ខធ្វើបាបពីមុនក៏មានរឿងថ្មីទៀត គឺកំណែន និងការបង់ប្រាក់ "ដោយស្ម័គ្រចិត្ត" ដើម្បីសមិទ្ធិថ្មីៗទៀតរបស់រដ្ឋាភិបាល ហើយនឹងការរឹបយកដីពីប្រជាជន យកទៅឲ្យមេទាហាន និងបង្កើតជំរុំកសិកម្មមួយរបស់ "យុវជនសង្គមរាស្ត្រនិយម"។ ម៉្យាងទៀតក៏មានការធ្វើឲ្យប្រជាជនមិនសប្បាយចិត្តអំពីការរឹបយកដីរបស់គាត់ ទៅធ្វើជាជំរុំពួកខ្មែរក្រោម ដែលអាកប្បកិរិយាពេលនោះ មិនខុសពីទាហានប៉ុន្មានទេ...។

ម៉្យាងទៀតកសិករនៅកន្លែងនោះស្អប់លោកលន់ នល់យូរហើយ ពីព្រោះលោកធ្លាប់ធ្វើជាចៅហ្វាយខេត្តបាត់ដំបង នៅពេលសង្គ្រាមឆ្នាំ១៩៥០។ ម៉្យាងទៀតគណៈកម្មាធិការសកម្មភាពទាំងនោះ ទាហានទាំងនោះដែលមានរឿងជាមួយកសិករនៅកន្លែងនោះ ត្រូវបានចាត់តាំងឡើងដោយបញ្ជា ឬបញ្ជូនមកពីភ្នំពេញ។ ជាការធម្មតាទេ ដែលកំហឹងរបស់កសិករនៅកន្លែង ចំពោះ "គណៈកម្មាធិការ" ទាំងនោះ ឬទាហានទាំងនោះ នាំឲ្យគេមានកំហឹងដល់ទៅភ្នំពេញ។ ពួកកុម្មុយនីស្ដនៅតំបន់នោះ ក៏ជាកសិករ ហើយក៏មានមនោសញ្ចេតនាមិនសប្បាយចិត្តអំពីការធ្វើទុក្ខ ធ្វើបាប និងរំលោភលើគេដូចកសិករដែរ។ ចំពោះគេក៏ដូចចំពោះកសិករនៅទីនោះដែរ ទាហានទាំងនោះ "ជាទាហានរបស់សីហនុ"។



ដូច្នេះសភាពការណ៍ធ្លាក់ចុះអាក្រក់យ៉ាងឆាប់រហ័ស។ ព្រឹកថ្ងៃ២ មេសា អ្នកភូមិសំឡូតមួយក្រុមក៏នាំគ្នាវាយទាហាន ធ្វើឲ្យ២នាក់ស្លាប់ ហើយយកអាវុធបានពីរដើម។ ហើយកសិករ២០០នាក់ទៀតក៏លើកគ្នាដើរឆ្ពោះទៅជំរុំកសិកម្មរបស់យុវជនសង្គមរាស្ត្រនិយមនៅក្រញូងដែលកសិករយល់ថា ជានិមិត្តរូបនៃការធ្វើទុក្ខធ្វើបាប និងរំលោភ ដែលគាត់ត្រូវរងគ្រោះពីសំណាក់រដ្ឋអំណាច ហើយក៏ដុតជំរុំនោះឲ្យឆេះអស់។ នៅពេលព្រលប់ ប៉ុស្តិ៍យោធាក្នុងភូមិ២ផ្សេងទៀតក៏ត្រូវបានវាយកំទេច ហើយមន្ត្រីឃុំម្នាក់ក៏ត្រូវសម្លាប់។ សកម្មភាពបះបោរ បានប្រព្រឹត្តទៅរយៈ៤ថ្ងៃ ស្ពាន២ ក៏ត្រូវបានដុតចោល ហើយមន្ត្រីម្នាក់ទៀត ក៏ត្រូវបានសម្លាប់។ ទើបមានការបញ្ជូនទាហានលោតឆ័ត្រមកដល់កន្លែង "ដើម្បីធ្វើឲ្យមានសន្តិភាពឡើងវិញ"។ នៅចុងខែមេសា កសិករ២០០នាក់ក៏ត្រូវចាប់បាន។ គេក៏ត្រូវវាយសួរចម្លើយ ផ្ទះ និងភូមិគេក៏ត្រូវបានដុតឆេះរាបនឹងដី។[១១៩] សម្ដេច ក៏យាងចុះមកមើលដល់កន្លែងចែកអំណោយខាងស្បៀងអាហារ និងសម្លៀកបំពាក់ ហើយលើកលែងទោសឲ្យអ្នកទាំងអស់ ប៉ុន្តែចំពោះពួកកសិករទាំងនោះ តើការសប្បុរសរបស់ព្រះមហាក្សត្រមានន័យអ្វីទៅ? គេពិបាកនឹងយល់អំពីថា តើនរណាជាអ្នកបញ្ជូនទាហានឆ័ត្រយោងទាំងអស់នេះ មកដល់ទីនេះ? សម្ដេចខ្លួនលោក? លោកលន់ នល់? ឬអ្នកទាំងពីរ? ទោះបីយ៉ាងណាក៏ដោយ អ្នកទាំងពីររួមគ្នានៅក្នុងរដ្ឋតែមួយ។ ដូច្នេះការវាយប្រហារទៅលើប៉ុស្តិ៍យោធាក៏នៅតែបន្ត ហើយអ្នកភូមិ ៣ភូមិទៀតក៏រត់ចេញពីផ្ទះទៅតាមអ្នកមុនៗ។ កម្មាភិបាលកុម្មុយនីស្ដក៏បានជូនដំណើរប្រជាជនកសិករវាង៥០០នាក់ អ្នកខ្លះប្រដាប់អាវុធ ហើយនាំគ្នាដកខ្លួនទៅភ្នំវាយចាប។ ជាតំបន់ដែលគ្របដណ្ដប់ទៅដោយព្រៃក្រាស់ ប្រហែល៣០គីឡូម៉ែត្រខាងជើងឈាងខាងកើតសំឡូត។ ប៉ុន្តែកងទ័ពបំពុលប្រភពទឹកទាំងអស់ ដណ្ដើមយក ឬកំទេចចោលស្រូវអង្ករដែលកសិករលាក់ទុក ហើយពាក់កណ្ដាលខែឧសភា សភាពការណ៍របស់គាត់ក៏ធ្លាក់ចុះលំបាកមែនទែន។

---

[១១៩] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៦៧

នៅពេលនោះ នួន ជា ក៏នាំសំបុត្រណៃនាំមួយពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាទៅឲ្យ រស់ ញឹម និង គង់ សុផល ឈ្មោះបដិវត្តន៍ (គឺ) "ឲ្យឈប់ច្បាំង ហើយចាប់ផ្តើមចរចាជាមួយសត្រូវ" ។ ក្រោយមកការចរចាក៏ចាប់ផ្តើមជាមួយនឹងចៅហ្វាយខេត្តបាត់ដំបង ដែលទើបតែងតាំងថ្មីឈ្មោះ អ៊ិន តាំ តាមរយៈលោកចៅអធិការវត្តថ្វាកនៅជិតភ្នំ។ លោកចៅហ្វាយខេត្តសន្យាថាមិនឲ្យមានការសងសឹកទេ ហើយមួយខែក្រោយមកគឺនៅថ្ងៃ១៨ មិថុនា សម្តេចព្រះអង្គក៏ប្រកាសថា ការបះបោរបានចប់សព្វគ្រប់ហើយ ?[១២០]

ប៉ុន្តែលើចំណុចនេះ អ្នកស្រាវជ្រាវទាំងអស់យល់ស្របគ្នាថា កិច្ចសន្យាថាមិនសងសឹកនោះ មិនបានគោរពតាមទេ។ ជាឧទាហរណ៍លោក បែន គៀរណាន់ បានដកស្រង់ លោក ហ្សាល មីយ័រដែលគាត់សរសេរថា៖ គឺចំពេលនោះ ហើយដែលកងទ័ពនិងកងជីវពលរបស់ខេត្តជ្រើសរើស ដើម្បីធ្វើប្រតិបត្តិការដាក់ទណ្ឌកម្ម! ភូមិត្រូវហ៊ុមព័ទ្ធ ប្រជាជនត្រូវគេបាញ់រះ ផ្ទះសម្បែងត្រូវដុតចោល...។[១២១]

ដូណាល់ ឡង់ កាស្ទើរ ជនជាតិអង់គ្លេសធ្វើការនៅការិយាល័យសម្តេចសរសេរថា៖ "សកម្មភាពយោធាដាក់ទណ្ឌកម្មលើប្រជាជន បានធ្វើឲ្យកសិករស្លាប់រាប់រយនាក់ ហើយធ្វើឲ្យកសិករសំឡូត និងតំបន់ជុំវិញចងកំហឹងជារៀងរហូតដល់របបនេះ។ កន្លែងដែលគេសង្ស័យថា ជាមូលដ្ឋានរបស់កុម្មុយនីស្តនៅក្នុងព្រៃ ត្រូវគេទំលាក់គ្រាប់បែក ភូមិត្រូវគេបាញ់រះ និងដុតចោលរាបនឹងដី...។ ការរាតត្បាតនៅក្នុងតំបន់បះបោរបានប្រព្រឹត្តទៅដោយកំរោល ដោយសារតែទាហានដែលគេសន្យាផ្តល់ជាលុយសម្រាប់ក្បាល (អ្នកបះបោរ) ដែលគេអាចយួរមកបង្ហាញនៅទីបញ្ជាការយោធា"។

[១២០] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៦៧

[១២១] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៦៧



"ព្រឹត្តិការណ៍សំឡូត ដែលគេធ្លាប់តែហៅយ៉ាងនេះតាំងពីពេលនោះមក បានធ្វើឲ្យកើតមានបញ្ហាជាច្រើន ទាំងចំពោះបក្សកុម្មុយនីស្ត ទាំងចំពោះសម្តេចនរោត្តម សីហនុ។

ចំពោះបក្សកុម្មុយនីស្តកម្ពុជា ការបះបោរកសិករនៅសំឡូតបញ្ជាក់ថាសភាពការណ៍ទំនាស់នៅក្នុងសង្គមទុំល្មម ដើម្បីគេចាប់ផ្តើមអនុវត្ត "នយោបាយមិនសន្តិភាពដើម្បីតស៊ូ" ដែលបានចូលជារបៀបវារៈតាំងពីឆ្នាំ១៩៦២ម៉េះ ប៉ុន្តែបក្សមិនទាន់បានរៀបចំខ្លួន ដើម្បីដឹកនាំចលនាបះបោរកំរិតទូទាំងប្រទេសនៅឡើយ។ វាជាការច្បាស់ណាស់ បើពេលនោះគេមិនបានរកការដោះស្រាយតាមការចរចាទេ ការបះបោរនៅសំឡូតនឹងត្រូវកំទេចដោយគ្មានត្រាប្រណីទេ។

ចំពោះសម្តេចនរោត្តមសីហនុវិញ ក៏មានការលំបាកក្នុងព្រះទ័យ។ ការដែលកសិករខ្មែរដែលព្រះអង្គធ្លាប់តែហៅថា ជាកូនចៅហ៊ានបះបោរងើបឡើងប្រឆាំងនឹងព្រះអង្គ-សម្តេចឪ-មិនអាចអត់ឱនឲ្យបានទេ ខាងនយោបាយ។

លោកយល់ថាការបះបោរនេះ គឺជាលទ្ធផលនៃការងាររបស់ពួកខ្មែរវៀតមិញ ដែលគេលាក់ទុកនៅពីក្រោយក្នុងមូលដ្ឋានខាងក្រោយកាលពីឆ្នាំ១៩៥៤ ហើយសំងំចាំតែពេលវេលានិងឱកាសអនុគ្រោះឲ្យគេ។ អ្នកដែលដឹកនាំពួកនោះនៅពីក្រោយឆាក គ្មានអ្នកណាក្រៅពីតំណាងរាស្ត្រខាងឆ្វេងទាំងបីនាក់នៅក្នុងសង្គមនោះទេ គឺខៀវ សំផន ហ៊ូ យន់ ហ៊ុយ នឹម ដែលជាអ្នកបង្កឲ្យមានរឿងរ៉ាវដោយចេតនា ដើម្បីធ្វើឲ្យរដ្ឋាភិបាលខាងស្តាំរបស់លោក លន់ នល់គ្មានការនឹងនរ។[១២២] តើសម្តេចលោកជឿជាក់យ៉ាងនេះមែន ឬមិនមែន នោះជារឿងមួយទៀតទេ ប៉ុន្តែលោកមានបន្ទូលយ៉ាងនេះហើយលោកនៅតែរក្សាបន្ទូលរបស់លោក។

[១២២] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៦៧

ថ្ងៃ២២ មេសា សម្ដេចក៏ប្រកាសតាមវិទ្យុថា សមាជិកសភាទាំងបីនាក់នេះអាចត្រូវបញ្ជូនទៅតុលាការយោធា។ ការប្រកាសនេះមិនអាចមើលស្រាលបានទេ។[១២៣]

មុននឹងយើងបន្តទៅទៀត ខ្ញុំយល់ឃើញថាជាការមានប្រយោជន៍ដើម្បីយើងពិនិត្យរៀនសូត្រខ្លះ ពីព្រឹត្តិការណ៍សំឡូតនេះ។

ជាដំបូងបង្អស់គួរគូសបញ្ជាក់ថា នៅចុងឆ្នាំ១៩៦៦ ដើមឆ្នាំ១៩៦៧ ព្រឹត្តិការណ៍សំឡូតមិនមែនជាព្រឹត្តិការណ៍ឯកោដោយឡែកទេ។

ឧទាហរណ៍នៅចុងម្ខាងទៀតនៃប្រទេស នៅក្នុងស្រុកក្រែកខេត្តកំពង់ចាម ភូមិកំណើតរបស់លោក សូ ភឹម ហៅថា ភូមិបុស ក៏ជាកម្មវត្ថុនៃការពាតត្បាតមួយយ៉ាងឃោរឃៅ។ លោកបែន គៀរណាន់ បានផ្សាយការដកស្រង់នៃសំភាសន៍របស់គាត់ជាមួយអតីតកម្មាភិបាលនៃភូមិភាគបូព៌ា ដែលហាក់ដូចជាការបញ្ចាំងអំពីសភាពការណ៍នៅពេលនោះ៖

តាមអ្នកភូមិម្នាក់ដែលនៅក្នុងព្រៃជាមួយលោកសូ ភឹម "ពួកវាមកតាមរកយើង...។ ទាហានសីហនុមកដល់ក៏សម្លាប់ អ្នកបដិវត្តន៍២៦នាក់នៅក្នុងភូមិ"។ ប្រភពមួយទៀត ក៏បានបញ្ជាក់ថាជនរងគ្រោះ ត្រូវបានគេកាត់ក្បាល ហើយថ្លើមរបស់គេត្រូវបានទាហានខ្វះយកចេញ។ កម្មាភិបាលទី៣នៃភូមិភាគបូព៌ា ដែលមានកំណើតនៅភូមិបុសដែរ ក៏បន្តទៀតថា "ហេតុដូច្នេះហើយបានជា (អ្នកដឹកនាំបដិវត្តន៍) បានប្រជុំមីទីងមួយហើយ សម្រេចប្រដាប់អាវុធប្រឆាំងសត្រូវវិញនៅខែកុម្ភៈ ១៩៦៧។ ពីមុនមកយើងសកម្មខាងនយោបាយ ប៉ុន្តែយើងគ្មានអាវុធទេ។ ឥឡូវយើងដណ្ដើមយកអាវុធ ហើយការតស៊ូអាវុធរួមផ្សំនយោបាយក៏ចាប់ផ្ដើម។ យើងបង្កើតក្រុមឃោសនាប្រដាប់អាវុធ រីតែកន្លែងណាដែលខ្មាំងវាស្ដើងនឹងប៉ុស្តិ៍តូចៗ ហើយពួនស្ទាក់

[១២៣] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៦៧



វាយតែតាមផ្លូវឆ្ងាយៗ។ យើងកម្ទេចភ្នាក់ងារខ្មាំងណាដែលវាសកម្មនៅតាមភូមិខ្លះក្នុងកណ្ដាលជ្រុំ។[១២៤]

បែន គៀរណាន់ បានឲ្យដឹងថា នៅទូទាំងប្រទេសនៅពេលនោះ គឺនៅចុងខែមេសា គេរាយការណ៍ថា "ខ្មែរវៀតមិញ" ២.០០០នាក់ ត្រូវចាប់បាន។[១២៥] ទី១ពាក្យថា "ខ្មែរវៀតមិញ" នៅចុងឆ្នាំ១៩៦៦ដើមឆ្នាំ១៩៦៧ គួរឲ្យអស់សំណើច។ ទី២តួលេខនេះខ្លួនវា ក៏វាឲ្យយើងដឹងអំពីទំហំនៃការពាតត្បាតនៅទូទាំងប្រទេសនៅពេលនោះ។

ហើយយើងសាកល្បងពិនិត្យតើព្រឹត្តិការណ៍ ដែលប្រជាជនបះបោរឡើងតវ៉ានៅសំឡូតនោះវាជារឿងអ្វី? ហើយប្រជាជននៅភូមិបុសដែលប៉ូលីស ឬទាហានចាប់ចង ហើយសម្លាប់វះពោះយកថ្លើម រូងយកប្រម៉ាត់នោះ វាជារឿងអ្វី? ជាការច្បាស់ណាស់ព្រឹត្តិការណ៍នៅសំឡូតដែលប្រជាជនកសិករបះបោរនោះ វាជារឿងសង្គម ឯព្រឹត្តិការណ៍នៅភូមិបុសវាជារឿងរំលោភលើកិច្ចព្រមព្រៀងហ្សឺណែវ តាំងពីឆ្នាំ១៩៥៤មក ដែលបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ហើយអនុញ្ញាតឲ្យអ្នកតស៊ូត្រឡប់មករស់នៅតាមភូមិស្រុកវិញ។ ហើយបើមានប្រព្រឹត្តខុសត្រូវអ្វី ក៏មិនត្រូវដល់ទៅសម្លាប់វះពោះ រូងយកថ្លើមដែរ។ ម្យ៉ាងទៀតបញ្ហាក៏ត្រូវចោទសួរដែរ តើចំពោះប្រជាជននៅសំឡូតក្ដី នៅភូមិបុសក្ដី និងនៅភូមិផ្សេងៗទៀតក្ដី តើឯករាជ្យរបស់ប្រទេសមានន័យថា ម៉េចទៅចំពោះផ្ទាល់ខ្លួនគេ? គឺគ្មានន័យអ្វីទាំងអស់ ឬសឹងតែទាំងអស់ គឺដូចតែនៅក្រោមអាណានិគមនិយមបារាំងដដែល។ គឺគេនៅត្រូវតែរ៉ាប់រងទំងន់ ឬសោហ៊ុយនៃការ "រីកចំរើន" នៅភ្នំពេញ ឬនៅក្នុងខេត្តផ្សេងទៀតទូទាំងប្រទេស។ គឺដូចតែនៅក្រោមអាណានិគមនិយមបារាំងដដែល គេនៅក្រោមទំងន់នៃការសង្កត់សង្កិននៃការប្រាក់ និងការបុលបណ្ដាក់។ នៅ

[១២៤] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៥៣

[១២៥] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៥៥

លើវិស័យនេះក៏គ្មានអ្វីផ្លាស់ប្តូរសោះទេ លើកលែងតែពេលនេះ គេជំពាក់លុយឈ្មួញស្លាកកណ្តាលចិន ហើយឈ្មួញស្លាកកណ្តាលចិនមកកើបយកស្រូវរបស់គេ ចំណែកឯពេលមុនគេជំពាក់លុយមន្ត្រីខ្មែរ ដែលជាមន្ត្រីរបស់ស្តេច។ កាលពីក្រោមអាណានិគមនិយមបារាំងគេធ្លាប់ស្គាល់មុខលោក លន់ នល់ ដែលធ្លាប់រំលោភធ្វើទុក្ខធ្វើបាបគេទៅហើយ។ ឥឡូវលន់ នល់ ក៏ត្រឡប់មកវិញម្តងទៀតដើម្បីរំលោភធ្វើទុក្ខធ្វើបាបគេដូចតែមុនទៀត។ ជីវភាពរស់នៅ របស់គេមិនត្រឹមតែមិនបានផ្លាស់ប្តូរប៉ុណ្ណោះទេ ប៉ុន្តែទុក្ខសោកវេទនារបស់គេមានតែបន្ថែមលើទុក្ខសោកវេទនាពីមុនមក។ ការមកដល់នៃទាហាន នៃ "គណៈកម្មាធិការសកម្មភាព" នៅខែកុម្ភៈ-មីនា ឆ្នាំ១៩៦៧ គ្រាន់តែជាតំណក់ទឹកមួយតូចដែលបានធ្វើឲ្យទឹកហៀរផើង។ ហើយព្រឹត្តិការណ៍សិស្សនៅសៀមរាបដែលបានផ្ទុះទៅជាបាតុកម្មសិស្សនៅឆ្នាំ១៩៦៣ ហើយក្លាយយ៉ាងឆាប់រហ័សទៅជាការបះបោរ ក៏ប្រហាក់ប្រហែលគ្នាដែរ គឺតាំងពីពេលនោះមកដែលទឹកវាហៀរកែវ។ ប៉ុន្តែអ្នកទទួលខុសត្រូវប្រទេសមើលងាយសភាពការណ៍ ហើយមិនពិនិត្យឲ្យបានដិតដល់។

ចំពោះមុខរឿងរ៉ាវ ដែលជារឿងរ៉ាវសង្គមគេឆ្លើយតបដោយការចាប់ចង រាតត្បាត។ នយោបាយបែបនេះ គឺវានាំទៅដល់ការបះបោរមិនខានទេ។ ដូច្នេះមិនបាច់លើកសំនួរដូចអ្នកនិពន្ធខ្លះបានលើកនោះទេ ដូចជាសួរថា "តើការរាតត្បាតរបស់រដ្ឋាភិបាល ជាមូលហេតុឬជាលទ្ធផលផ្ទាល់នៃសញ្ញាដំបូងនៃសង្គ្រាមស៊ីវិល? "ហើយក៏មិនបាច់សួររកវែងឆ្ងាយអំពីព្រឹត្តិការណ៍តមកទៀត ដូចជាការងើបឡើងតស៊ូនៅឆ្នាំ១៩៦៨ជាដើមនោះទេ។ ព្រឹត្តិការណ៍ទាំងអស់នេះ មិនអាចជាអំពើរបស់មនុស្សម្នាក់ ឬក្រុមមនុស្សតូចមួយនោះទេ មិនចាំបាច់ទៅចាប់ពពែមកលាបមាត់ទេ។ ខ្ញុំយល់ថា នេះជាមេរៀនទី១ ហើយមេរៀននេះ ក៏មិនចាំបាច់គូសបញ្ជាក់អំពីសារៈសំខាន់របស់វានោះទេ។

មេរៀនទី២ គឺករណីនៃបញ្ញាជន ដូចជារូបខ្ញុំ និងលោក ហ៊ូ យន់ និងបញ្ញាជនផ្សេងទៀត។ វាបញ្ជាក់ច្បាស់ណាស់អំពី "ជំងឺរបស់ខ្មែរ"។ រដ្ឋមិន



អនុញ្ញាតឲ្យមានឯករាជ្យខាងគំនិតគិតគូរទាល់តែសោះ។ នេះហើយដែលនាំឲ្យកើតជាជំងឺ "មនុស្សមិន ចេះគិតគូរ" សូត្រតាមតែអ្វីដែលគេឲ្យសូត្រ និងជំងឺពុករលួយនៃនាម៉ឺនមន្ត្រីអ្នករដ្ឋការ ជំងឺបាក់បបក្ខបខ្វាចអ្នកធំ...។ ជំងឺនេះក៏មិនបាច់ទៅរកឬសគល់ឯណាវែងឆ្ងាយដែរ។

ជំងឺទាំងពីរខាងលើនេះជាជំងឺសង្គមសក្តិភូមិ។ នៅចំពោះមុខយថាហេតុនៃការត្រូវចាប់បញ្ជូនទៅឲ្យតុលាការយោធា លោកហ៊ូ យន់ និងលោក ខៀវ សំផន ក៏រត់ចេញពីទីក្រុងភ្នំពេញនៅថ្ងៃ២៤ មេសា ឆ្នាំ១៩៦៧។ ប៉ុន្តែការបាត់មុខរបស់អ្នកទាំងពីរ ក៏បណ្តាលឲ្យមានការសង្ស័យថា ប៉ូលីសសំងាត់បានលួចសម្លាប់គេ ហើយក៏បណ្តាលឲ្យមានវិបត្តិនយោបាយយ៉ាងធ្ងន់ធ្ងរ បង្ខំឲ្យលោកលន់ នល់លាឈប់។ សម្តេចផ្ទាល់ខ្លួនលោក ក៏ដឹកនាំរដ្ឋាភិបាលថ្មីដែលមានឥស្សរជនកណ្តាល ដូចជាឯកឧត្តម សឺន សាន អ្នកដឹកនាំចាស់នៃគណបក្សប្រជាធិបតេយ្យ អ្នកអង្គម្ចាស់នរោត្តមភូរីស្សារ៉ា...។ ដោយមានការផ្លាស់ប្តូរយ៉ាងនេះលោក វន វេត ដែលជាអ្នកដឹកនាំមួយរូបនៃបក្សកុម្មុយនីស្តកម្ពុជា ហើយដែលនៅធ្វើការនៅភ្នំពេញនៅឡើយ ក៏ខិតខំពន្យល់លោកហ៊ុយ នឹម ដែលពេលនោះចង់រត់ចេញពីភ្នំពេញដែរ ឲ្យគាត់ផ្អាកសិនរង់ចាំមើលការវិវត្តន៍នៃសភាពការណ៍សិន។

បីបួនថ្ងៃក្រោយមកលោកហ៊ុយ នឹមក៏បានផ្សាយសេក្តីថ្លែងការណ៍របស់លោកអំពីសេចក្តីស្មោះត្រង់របស់លោកចំពោះសម្តេច។ ប៉ុន្តែសភាពការណ៍វិវត្តន៍មកដល់នេះហើយ ពីបាកនឹងថយក្រោយវិញណាស់ ទោះបីគណៈកម្មាធិការមជ្ឈឹមរបស់បក្សកុម្មុយនិស្តកម្ពុជាចង់ក៏ដោយ។ នៅពេលដែលលោកហ៊ុយ នឹមថ្លែងការណ៍ហើយ ថ្លែងការណ៍ទៀតអំពីសេចក្តីស្មោះត្រង់របស់លោក ខិតប័ណ្ណដែលគេចែកចាយនៅកំពង់ធំ ទំលាក់កំហុសទៅលើសម្តេចអំពីការបាត់ខ្លួនរបស់លោកទាំងពីរ ហើយអំពាវនាវឲ្យប្រជាជនក្រោកឈរឡើងបះបោរ។[១២៦] ប៉ុន្មានថ្ងៃក្រោយមកទៀត គឺនៅដើមខែឧសភា នៅ

[១២៦] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៦១

ពេលដែលសម្តេចយាងទៅសំឡូត ពួកបះបោរ "បានជេរប្រមាថដោយពាក្យធំៗ ដែលលោកពុំអាចទ្រាំទទួលបានទេ"ៗ[១២៧] ក្រោយមកដល់លោកយាងមកដល់ផ្លូង លោកត្រូវចោទថា "មានទិសដៅយកកម្ពុជាទៅធ្វើជារណបរបស់ចក្រពត្តិអាមេរិកៗ[១២៨] លើសពីនេះទៅទៀត ពេលនោះនៅព្រៃទទឹងដែលជាមណ្ឌលរបស់លោក ហ៊ុ នឹម ការបះបោរមួយក៏បានផ្ទុះឡើង ហើយឡានដឹកមនុស្សមួយក៏ត្រូវបានដុតឆេះៗ

ថ្ងៃ២ កញ្ញា ក្រោយពីបានធ្វើការវាយប្រហារមួយទៅលើលោក ហ៊ុយ នឹម សម្តេច ក៏បានប្រកាសរំលាយចោលសមាគមមិត្តភាពខ្មែរ-ចិន ដែលលោកធ្វើជាប្រធាន ៗ

ថ្ងៃ៣០ កញ្ញា សម្តេចក៏បានកោះប្រជុំមិទិញពិសេសមួយនៅវិទ្យាល័យព្រៃទទឹង ដើម្បីចោទលោកហ៊ុយ នឹមនៅចំពោះមុខអ្នកបោះឆ្នោតរបស់លោកៗ សម្តេចចាប់ផ្តើមជេរប្រមាថលោកហ៊ុយ នឹមថា លោកមានមុខដូចយួន ឬចិនៗ ហើយលោកក៏សន្និដ្ឋានជាទីបញ្ចប់ថា "លោកហ៊ុយ នឹម និងសហការីរបស់លោកបានកំចាត់ខ្លួនលោកចេញពីជាតិ ហើយលោកឲ្យដំបូន្មានថា ឲ្យទៅរស់នៅ នៅចិនៗ[១២៩]

ពីរថ្ងៃក្រោយមកលោកហ៊ុយ នឹម ក៏បានទទួលសំបុត្រមួយពីលោកវនវេតឲ្យត្រៀមរៀបចំខ្លួនចេញនៅថ្ងៃ៧ តុលាៗ

មិនយូរប៉ុន្មានក្រោយមកទៀតលោក គោគ ឆាយ ប្រធាននៃសមាគមទូទៅនៃនិស្សិតខ្មែរក៏ត្រូវចាប់ ហើយត្រូវផ្តន្ទាទោសប្រហារជីវិត ប៉ុន្តែថ្ងៃក្រោយទៅទោសនេះ ក៏ត្រូវសំរាលឲ្យមកជាប់គុកអស់មួយជីវិតវិញ ហើយសមាគមក៏ត្រូវបិទៗ លោក វ៉ាន់ ទិពសាវណ្ណ ម្ចាស់រោងពុម្ពដែលបានបោះពុម្ពឲ្យកាសែត

[១២៧] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ១៥៦

[១២៨] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៥៦

[១២៩] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៦៤



ប្រជាជន ក៏ត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់នៅទីស្តីការកណ្តាលរបស់ប៉ូលីសសម្ងាត់ៗ

អ្នកប្រវត្តិសាស្ត្រអូស្ត្រាលីម្នាក់ដែលបានមកធ្វើទស្សនកិច្ចនៅភ្នំពេញបានសរសេរថា "គេនាំគ្នានិយាយដោយស្ងប់ខ្ញើមផងលាយឡំនឹងការភ័យខ្លាចនឹងការចំអក អំពីវិធីផុយៗដែលក្រសួងសន្តិសុខរបស់សីហនុ បានប្រើៗ

កាលពីឆ្នាំ១៩៦៥ មានតែបញ្ញាជនមួយនាក់ ពីរនាក់ប៉ុណ្ណោះដែលបានចូលព្រៃម៉ាគីៗ ដល់ឆ្នាំ១៩៦៧ ក៏ក្លាយទៅជាចរន្តមួយសំខាន់ៗ គេទៅនេះមិនមែនដោយខ្លាចស្លាប់ទេ ប៉ុន្តែដោយគេមានជំនឿមួយជឿជាក់ថាត្រូវតែមានការផ្លាស់ប្តូរមួយយ៉ាងជ្រាលជ្រៅដោយជៀសមិនផុតៗ[១៣០]

### ត- ការងើបឡើងតស៊ូអាវុធជាទូទៅនៅឆ្នាំ ១៩៦៨

នៅដើមឆ្នាំ១៩៦៨ បក្សកុម្មុយនីស្តកម្ពុជា ក៏ចាប់ផ្តើមបើកឆាកតស៊ូអាវុធប្រកបទៅដោយជោគជ័យៗ[១៣១] សម្តេចក៏មិននឹកស្មានដល់សមត្ថភាពនៃកម្លាំងខ្មែរក្រហមខាងចាត់តាំងយ៉ាងនេះដែរៗ ក្រោយមកសម្តេចមានបន្ទូល "អំពីប្រតិបត្តិការមួយដែលស្រុះគ្នាប្រឆាំងនឹងកងទ័ពយើងដែលឯកោ" "គឺចលនាតែមួយ យុទ្ធវិធីតែមួយ បានត្រូវប្រើនៅបាត់ដំបង តាកែវ កំពង់ឆ្នាំង កំពត កំពង់ស្ពឺ កោះកុង..."ៗ "សំខាន់ជាងនេះទៅទៀត គឺប្រជាជនជាង ១០០០នាក់នៅបាត់ដំបង កំពត កំពង់ឆ្នាំង រត់ចូលព្រៃតាមពួកបះបោរនៅដើមខែមីនា សម្តេចប្រកាសថា "ដូច្នេះសូមអស់លោកជួយមើល គឺសង្គ្រាមពេញទំហឹងហើយ...ៗ[១៣២]

[១៣០] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៦៨ (អ្នកនិពន្ធយោងទៅលោក មីលតុន អុសបូន សីហនុ "ស្តេចដែលមានពន្លឺ និងស្តេចដែលនាំមកនូវភាពងងឹត" ទំព័រ១៧៦ និង ទំព័រ១៩៦-៩៧)

[១៣១] ខៀវ សំផន "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ទំព័រ៣៧-៣៩

[១៣២] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៧០

ដោយកម្លាំងខាងស្តាំហ៊ុមព័ទ្ធសម្តេចជាប់ហើយ ទោះបីលោក លន់ នល់ លាលែងចេញពីតំណែងនាយករដ្ឋមន្ត្រីហើយក៏ដោយ សភាពការណ៍រួម មិនមានអ្វីប្រែប្រួលទេ។ ឧទាហរណ៍នៅខែមិថុនា នៅឆ្នាំ១៩៦៨ "សភាជាតិវាយប្រហារទៅលើសម្តេចថា មនុស្សស្លូតត្រង់ ដែលមិនមែនជាខ្មែរក្រហមសោះ ត្រូវបានគេចាប់ចង និងសម្លាប់ "ដោយផ្ទុយ និងរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ...។[១៣៣] ការពិតការចាប់ចង និងសម្លាប់នោះ គឺជាអំពើប្រព្រឹត្តរបស់ "គណៈកម្មាធិការសកម្មភាព" ដែល "សភាជាតិ" យកមកទម្លាក់លើសម្តេច។

នៅភ្នំពេញ ខិត្តប័ណ្ណកុម្មុយនីស្តនៅតែមានផ្សាយពាសពេញ។ មានផ្សាយរហូតដល់ប្រតិភូនៃសមាជរបស់សង្គម។ លោកលន់ នល់ ដែលទើបគេចាត់តាំងឲ្យធ្វើជារដ្ឋមន្ត្រីការពារប្រទេសវិញ ក៏រៀបចំកម្លាំងឲ្យចុះទៅឆែកឆេរ។ នៅពេលមួយដែលប៉ូលីសចុះទៅ ក៏មានបាញ់គ្នានៅក្នុងក្រុង ហើយកម្មាភិបាលម្នាក់ឈ្មោះ កាក់ ស៊ីម ត្រូវស្លាប់ដើម្បីការពារលោកវ៉ន វេត។ អ្នកដែលត្រូវគេសង្ស័យចំនួន៤០នាក់ ភាគច្រើនជានិស្សិតដែលបានបោះបង់ចោលការរៀនសូត្រ ហើយបានធ្វើការជាគ្រូលីគេ ជាអ្នកជាក់ស៊ីក្លូ ប៉ុន្តែក៏មានអ្នកខ្លះធ្វើជាមន្ត្រីខាងសាធារណការ ខាងប៉ុស្តិ៍ទូរស័ព្ទ និងទូរលេខនៅក្នុងធនាគារជាតិ នៅក្នុងរដ្ឋាការរទេះភ្លើង ហើយរហូតដល់នៅក្នុងក្រសួងយុត្តិធម៌ "ត្រូវចាប់ និងសម្លាប់ចោល។ តាមកាសែតរដ្ឋាភិបាល ឈ្មោះ Réalités Cambodgiennes មានរហូតដល់នារីម្នាក់ "ដែលលាក់សារសម្ងាត់នៅក្នុងអាវទ្រនាប់ និងខោទ្រនាប់របស់ខ្លួន"។ សំខាន់ជាងនេះទៅទៀត គឺប៉ូលីសរកឃើញប្រដាប់វះកាត់២ សម្រាប់អាវុធ និង គ្រាប់រំសេវ ម៉ាស៊ីនសម្រាប់វាយអត្ថបទ ដែលរង់ចាំតែគេផ្ញើទៅព្រៃ និងខិត្តប័ណ្ណ ហើយវិទ្យុផ្សាយសំឡេងមានកម្លាំងខ្លាំង រួមទាំងវិទ្យុផ្សាយសំឡេងមួយ ដែលប្រើរលកអាកាសដូចក្រសួងសន្តិសុខនៃដំណាក់របស់សម្តេចផង។[១៣៤]

[១៣៣] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៧៦

[១៣៤] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៨៣



ការចុះវាតត្បាតនៅថ្ងៃនោះ មិនបានធ្វើឲ្យបណ្តាញសម្ងាត់របស់ពួកបះបោរនៅភ្នំពេញខូចខាតប៉ុន្មានទេ។ មិនយូរប៉ុន្មានទេ លោក វ៉ន វេត បានព្យាយាមជួសជុលក្រឡាសំណាញ់ដែលខូចខាតបានឡើងវិញ។ លោក នួន ជា ដែលរដ្ឋអំណាច មិនដែលរកឃើញសោះនៅតែបន្តបំពេញភារកិច្ចសំខាន់របស់លោកតទៅទៀត -ដោយប្រើរូបភាពជាអ្នកជំនួញជួញដូរ ដើរទៅនេះដើរទៅនោះជាប់ ដើម្បីបញ្ជូនកាំភ្លើង គ្រាប់បែកដៃ និងគ្រាប់រំសេវ ដល់ពួកបះបោរនៅក្នុងព្រៃ។[១៣៥] ប៉ុន្តែការឆែកឆេររកឃើញនេះបានបង្ហាញនូវសមត្ថភាពពួកបះបោរ ដើម្បីលាតសន្ធឹងប្រមោយរបស់គេយ៉ាងច្រើនចូលដល់ក្នុងរាជធានី។[១៣៦] វារឹតតែធ្វើឲ្យអ្នកនយោបាយនៅភ្នំពេញកាន់តែញាប់ញ័ររន្ធត់ភ័យខ្លាចថែមទៀត។ ចំពោះអ្នកនយោបាយទាំងនោះ មានតែលោកលន់ នល់ ទេដែលជាមនុស្សខ្លាំង អាចប្រឈមមុខនឹងសភាពការណ៍ទាំងនេះបាន។ នៅខែធ្នូ ឆ្នាំ១៩៦៩ លោកលន់ នល់ ក៏ត្រូវតែងតាំងជានាយករដ្ឋមន្ត្រីបណ្តោះអាសន្ន ដើម្បីអមលោកតា ប៉ែន នុត ដែលកំពុងតែឈឺ។ ៧ខែក្រោយមកទៀត ក៏ លោក លន់ នល់ នៅតែបន្តកាន់កាប់តំណែងនេះព្រមជាមួយ និងតំណែងរដ្ឋមន្ត្រីការពារប្រទេស និងជានាយអគ្គសេនាធិការបណ្តោះអាសន្ន។ គឺជាលើកទីមួយហើយ ដែលសម្តេចអនុញ្ញាតឲ្យមនុស្សម្នាក់ទទួលកាន់កាប់តំណែងយោធា និងស៊ីវិលខ្ពស់ៗតែម្នាក់ឯងយ៉ាងនេះ។ លោកគ្មានផ្លូវជ្រើសរើសទៀតទេ។[១៣៧]

នៅផ្នែកខាងការទាក់ទងបរទេស កម្លាំងសង្កត់របស់សហរដ្ឋអាមេរិកក៏ដាក់ទម្ងន់កាន់តែធ្ងន់មកលើសម្តេចដែរ។ សម្តេចនៅតែជឿថា ទោះបីយ៉ាងណាក៏ដោយ អាមេរិកត្រូវតែចាញ់សង្គ្រាមហើយ ហើយយុទ្ធសាស្ត្រ

[១៣៥] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៨១

[១៣៦] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៨២

[១៣៧] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៨៤

របស់លោកដែលខំប្រមូលសាគុណលើពួកកុម្មុយនីស្ត ដែលជាអ្នកឈ្នះទៅអនាគត់នោះជាការត្រឹមត្រូវ។ ប៉ុន្តែពេលនេះ លទ្ធភាពដាក់ផរបស់លោកកាន់តែចង្អៀតណាស់ទៅហើយ។ លោកត្រូវតែធ្វើកាយវិការមួយដល់សហរដ្ឋអាមេរិកវិញ។ នេះហើយដែលលោកហៅថា "ដើរលើខ្សែពួរដែលការពិតនាំឲ្យមានគ្រោះថ្នាក់ច្រើនណាស់។

លោក ក៏ចាប់ផ្តើមអញ្ជើញលោកស្រី យ៉ាក់គីលីន កេណេឌី មកឲ្យធ្វើទស្សនកិច្ចជាឯកជននៅខែតុលា។ ទស្សនកិច្ចនេះ ទទួលបានជោគជ័យ។ តមកទៀត លោក ឆេស ស្ទែរ បូវលេស តំណាងពិសេសរបស់ប្រធានាធិបតីនិចសន់ ក៏ត្រូវអញ្ជើញមកទៀតនៅខែមករា។ ម្តងនេះ ភ្ញៀវនេះមិនមែនគ្រាន់តែអញ្ជើញមកដើរលេងទេ។ តាមវិមានសឥស្សរៈជនទាំងពីរនាក់បានឈានដល់កិច្ចព្រមព្រៀងក្រៅផ្លូវការ អនុញ្ញាតឲ្យកម្លាំងអាមេរិកចូលមកក្នុងព្រំដែន ដែលមិនសូវមានមនុស្សរស់នៅ គឺរតនៈគីរី និងមណ្ឌលគីរី ក្នុងការដេញតាមពួកឈ្លបវៀតកុង លើកលែងតែតំបន់ដែលមានមនុស្សកុះករនៅខាងត្បូង។[១៣៨]

នៅខែមីនា ឆ្នាំ១៩៦៩ លោកប្រធានាធិបតី និកសុន យល់ឃើញថាមិនចាំបាច់សួរមតិសម្តេចផងទេ។ លោកបញ្ជាឲ្យកងជើងអាកាសសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកស្ងាត់ៗ នៅកន្លែងដែលពួកវៀតកុងជ្រកនៅក្នុងស្រុកខ្មែរ។ នៅក្នុងរយៈ១២ខែតទៅមុខទៀតនេះ យន្តហោះបេ៥២ បានបញ្ចេញទម្លាក់គ្រាប់បែក៣០០០លើកលើផ្នែកខាងកើតនៃប្រទេសកម្ពុជា តាមប្រតិបត្តិការមួយមានឈ្មោះហៅថា "មើនុយ"។[១៣៩] សម្តេចមិនតវ៉ាទេ។ មិនមែនមកពីលោកយល់ស្របទេ ប៉ុន្តែមកពីសភាពការណ៍បានតម្រូវឲ្យលោកជួសជុលការទាក់ទងជាមួយអាមេរិក ដូច្នេះលោកត្រូវតែនៅស្ងៀម។

[១៣៨] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៨១

[១៣៩] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៨២



នៅពេលដែលសម្តេចយាងទៅចូលរួមបុណ្យសពហូជីមិញ សម្តេចបានព្រមានអ្នកដឹកនាំវៀតណាមយ៉ាងច្បាស់ថា បើគេទាំងឡាយចង់ឲ្យកម្ពុជានៅជាអព្យាក្រឹត្យ ហើយបើកចំហដល់ការដឹកជញ្ជូនអាវុធនិងគ្រាប់រំសេវដល់ពួកវៀតកុង គេទាំងឡាយត្រូវបង្ហាញនូវការគាំទ្ររបស់គេ ចំពោះសម្តេច។ ប៉ុន្តែពេលនោះ មេដឹកនាំវៀតណាមបាត់ម្ចាស់ការអស់ហើយ។ គេចងកំហឹងចំពោះប៉ុលពតមិនតិចទេ។ កំហឹងនេះផ្ទុះឡើងជាចំហរនៅពេលដែលឡេយន់ជួបលោកសាឡុតស នៅចុងឆ្នាំ១៩៦៩។ គឺចាប់ពីពេលនោះហើយដែលគេកំណត់ថា ប៉ុលពតមិនមែនជាសម្ពន្ធមិត្តជាទីគាប់ចិត្តរបស់គេទេ។ កំហឹងនេះបានធូស្បើយមកវិញ ក្រោយពីរដ្ឋប្រហារ និងក្រោយពីកើតមានសម្ព័ន្ធភាពរវាងសម្តេចនរោត្តមសីហនុ និងពួកកុម្មុយនីស្តខ្មែរ។ សម្ព័ន្ធភាពនេះ ប្រែទៅជាផលប្រយោជន៍សម្រាប់ទាំងអស់គ្នាទៅវិញ។ ប៉ុន្តែការធូស្បើយនេះមិនបានយូរប៉ុន្មានទេ។ ទំនាស់ចាប់ផ្តើមរើឡើងវិញមិនប៉ុន្មានថ្ងៃក្រោយមកទៀតនេះ គឺក្រោយពីលោកសាឡុតស ប្រកែកមិនព្រមទទួលការស្នើរបស់ឡេ យន់ឲ្យចាត់តាំងបញ្ជាការចម្រុះ និងក្រោយពីមានការប៉ះទង្គិចគ្នាជាមួយកម្លាំងវៀតណាមនៅក្នុងដីកម្ពុជាតៗមកទៀត។ ទំនាស់លើកនេះមិនចេញជាចំហទៀតទេ។ វៀតណាមចេះតែសម្រួល ពីព្រោះគេត្រូវការទឹកដីកម្ពុជា ប៉ុន្តែទំនាស់វានៅដដែល។ គេគំទុកចាំដល់ពេលគេស្រឡះដៃស្រឡះជើង។

## ច-លក្ខណៈសម្បត្តិដើម្បីធ្វើរដ្ឋប្រហារ មានសព្វគ្រប់អស់ហើយ

ដល់ខែកក្កដាឆ្នាំ១៩៦៩ សម្តេចត្រូវតែប្រថាប់ត្រា លោក លន់ នល់ ជានាយករដ្ឋមន្ត្រីពេញសិទ្ធិ។[១៤០] លោក ម៉ៃឃើល រីវ ដែលជារងរបស់ទូតអាមេរិកត្រូវអញ្ជើញមកដល់ខែក្រោយហើយ។ បើកម្ពុជាចង់ឲ្យអាមេរិកយកជាការបាន កម្ពុជាពុំអាចនៅក្រោមរដ្ឋាភិបាលបណ្តោះអាសន្នទៀតទេ។

[១៤០] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៨៥

ចំណែកឯពួកខ្មែរក្រហមវិញ គេក៏មិនឃើញមានសញ្ញាអ្វីថា គេនឹងថយសោះ។ ចំណែកឯពួកកុម្មុយនីស្តវៀតណាមវិញ កម្លាំងរបស់គេ ក៏បានកើនឡើងច្រើនសន្ធឹកសន្ធាប់ គឺពីចំនួន៦.០០០នាក់នៅពាក់កណ្តាលឆ្នាំ១៩៦៨ កម្លាំងនេះកើនដល់ប្រហែល៣០.០០០នាក់ ១ឆ្នាំក្រោយមក។ ការទម្លាក់គ្រាប់បែកសម្ងាត់ "មេនុយ" មិនត្រឹមតែបរាជ័យក្នុងបេសកកម្មសំខាន់របស់វាប៉ុណ្ណោះទេ -ទីបញ្ជាការរបស់កងទ័ពវៀតណាម សម្រាប់ដឹកនាំការប្រយុទ្ធនៅខាងត្បូងក្តី មូលដ្ឋានរបស់វៀតកុងក្តី អត់បានត្រូវកំទេចទេ - ប៉ុន្តែកាន់តែជំរុញពួកកុម្មុយនីស្តវៀតណាម ឲ្យចូលមកក្នុងប្រទេសកម្ពុជាកាន់តែច្រើនថែមទៀត។ គឺក្នុងសភាពការណ៍នេះហើយដែល លោក លន់ នល់ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៃ "រដ្ឋាភិបាលស្រោចស្រង់ និងសង្គ្រោះជាតិ"។ សម្តេច នរោត្តម សីហនុប្រកាសថា នាយករដ្ឋមន្ត្រីអាចធ្វើអ្វីៗទាំងអស់បានតាមខ្លួនមើលឃើញថា ចាំបាច់ដើម្បីស្រោចស្រង់ឡើងវិញនូវសេដ្ឋកិច្ចដែលមានជម្ងឺធ្ងន់ណាស់ទៅហើយ ហើយដើម្បីបញ្ចប់ការបះបោររបស់ខ្មែរក្រហម។ លក្ខខណ្ឌមានតែមួយទេ គឺត្រូវរក្សានយោបាយអព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធណា។ ប៉ុន្តែមកដល់ថ្មើរនេះទៅហើយ លក្ខខណ្ឌនេះព្រះអង្គក៏យល់ដែរថា គ្រាន់តែដើម្បីឲ្យតែពីរោះស្តាប់ទេ។

សម្តេច ក៏ត្រូវដកថយលើបញ្ហាសេដ្ឋកិច្ច និងសង្គមដែរ។ ក្នុងខែធ្នូដដែលនោះលោកប្រកាសថា កម្មវិធីជាតូបនីយកម្ម និងការត្រួតត្រារបស់រដ្ឋ លើពាណិជ្ជកម្មក្រៅប្រទេស ដែលបានអនុវត្តតាំងពី៥ឆ្នាំមុន ក៏ត្រូវកែប្រែដែរ ដើម្បីបើកឲ្យសេដ្ឋកិច្ចឯកជន មានតួនាទីធំទូលាយ ហើយជំនួយមកពីខាងណា ក៏រដ្ឋាភិបាលទទួលយកដែរ។[១៤១] ការពិតលើការកែទម្រង់ពីឆ្នាំ១៩៦៣ បែន គៀរណាន់ បានសរសេរដូចតទៅ ៖

"លើបញ្ហានេះ សញ្ញាបានលេចចេញរួចហើយ កាលពីឆ្នាំ១៩៦៣៖ ការប្រមូលកាត់ទទួលបានផលខ្ពស់ ហើយដល់ឆ្នាំ១៩៦៤ លទ្ធផលក៏ទទួល

[១៤១] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៨៥



បានខ្ពស់ជាងឆ្នាំ១៩៦៣ថែមទៀត។ ការនាំស្រូវចេញបានកើនឡើងៗ ជាលើកទីមួយហើយ តាំងពីឆ្នាំ១៩៥៥មក ជញ្ជីងពាណិជ្ជកម្មរបស់ប្រទេសបានចំណេញ ហើយនៅឆ្នាំ១៩៦៥ រូបិយប័ណ្ណទុកបំរុងនៅធានាគារជាតិបានកើនឡើង ក្រោយពីការធ្លាក់ចុះយូរឆ្នាំមកហើយ។ ដូច្នេះការកែទម្រង់ជាជោគជ័យខាងសេដ្ឋកិច្ចមួយយ៉ាងច្បាស់។ គឺដល់ឆ្នាំ១៩៦៦នោះទេ ក្រោយពីការឈានឡើងនៃសង្គ្រាមវៀតណាម និងក្រោយដែលមួយភាគធំនៃស្រូវរបស់ខ្មែរត្រូវបានរត់គយឆ្លងកាត់ព្រំដែន និងក្រោយពីស្រូវដែលបាននាំចេញដោយបង់ពន្ធត្រូវធ្លាក់ចុះអស់២ភាគ៣ ដែលនាំឲ្យរដ្ឋរបស់សីហនុសំយុងក្បាលចុះទៅរកការរលំរលាយ។[១៤២]

នៅពេលដែលខ្ញុំ បានស្នើគំរោងកែទម្រង់របស់ខ្ញុំទៅថ្វាយសម្តេចព្រះប្រមុខរដ្ឋតាមរយៈសព់ឯកឧត្តមសឺន សាន (ពេលនោះ ឯកឧត្តមធ្វើជាប្រធានធនាគារជាតិ ឯខ្ញុំ ខ្ញុំនៅធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មឆ្នាំ១៩៦៣) ខ្ញុំជឿជាក់ថា ក្នុងក្របខណ្ឌនៃនយោបាយឯករាជ្យអព្យាក្រឹត្យរបស់សម្តេច មូលធននិយមជាតិ មានលទ្ធភាពជាច្រើននឹងរីកលូតលាស់ ដើម្បីផលប្រយោជន៍ជាតិ ឲ្យតែរដ្ឋផ្តល់ឲ្យគេនូវជំនួយ និងការឧបត្ថម្ភជាចាំបាច់។ ដើម្បីឧបត្ថមនាយទុនជាតិបាន ចាំបាច់ត្រូវតែប្រយុទ្ធដោយម៉ឺងម៉ាត់ ប្រឆាំងនិងក្រុមផលប្រយោជន៍ផ្សេងៗ។ ចំណែកឯជំនួយពីខាងក្រៅក៏ត្រូវតែតម្រូវទៅតាមការចាំបាច់នេះរបស់ជាតិដែរ។

អ្វីដែលលោកបែន គៀរណានបានសរសេរខាងក្រោមនេះ ជាគំរូយ៉ាងជាក់ច្បាស់នៃសកម្មភាពនៃក្រុមផលប្រយោជន៍ដែលខ្ញុំនិយាយនេះ ៖

"នៅឆ្នាំ១៩៦៩ អ្នកសេដ្ឋកិច្ចអភិរក្សខ្មែរម្នាក់បានសរសេរអំពីសកម្មភាពឈ្មួញខិលខូចឈ្លៀតកេងចំណេញ នៅពេលដែលកសិករត្រូវចុះព្យួរនៅរដូវដើមឆ្នាំ។ នៅជុំវិញខែកញ្ញា ឆ្នាំ១៩៦៨ នាយទុនខ្លះក៏មកនិយាយបញ្ចុះ

[១៤២] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២០៩

បញ្ចូលរដ្ឋាភិបាលឲ្យតម្លើងថ្លៃអង្ករបន្តិច (ដើម្បីលើកទឹកចិត្តកសិករ)។ ឯលទ្ធផលវាផ្ទុយពីនេះទៅវិញ។ គឺឈ្មួញស្ពានកណ្ដាល និងអ្នកលក់អង្ករទេ ដែលបានផលចំណេញពីការតម្លើងថ្លៃអង្ករ។ ឯនៅខែកញ្ញា កសិករបានលក់ស្រូវរបស់ខ្លួនអស់ទៅហើយ ហើយត្រូវទៅទិញអង្ករ ដើម្បីយកមកចិញ្ចឹមគ្រួសារវិញ។ មួយឆ្នាំក្រោយទៀត ប្រាក់រៀលក៏ត្រូវបញ្ចុះថ្លៃនៅពេលនេះទៀត ហើយការដែលអង្ករឡើងថ្លៃ ក៏បានបណ្ដាលឲ្យមានលទ្ធផលដូចគ្នានេះទៀត ដែលជាហេតុតាមអ្នកនិពន្ធនៃអត្ថបទបានសរសេរ "នាំឲ្យកសិករកាន់តែខឹងសម្បារយ៉ាងខ្លាំងថែមទៀត"។[១៤៣]

ការពិត ការតម្លើងថ្លៃអង្ករនៅពេលណាក៏ដោយ ក៏មិនអាចបានផលចំណេញទៅកសិករដែរ ពីព្រោះសព្វថ្ងៃនេះ ក៏ដោយកសិករភាគច្រើនលើសលុបជំពាក់បំណុលគេ ស្រូវរបស់គាត់ច្រូតកាត់មិនទាន់ហើយស្រលបួលផងក៏ត្រូវម្ចាស់បំណុលមកកើបយកអស់ហើយ ដោយគេគិតទាំងដើមទាំងការ។ កសិករក្រត្រូវខ្ចីស្រូវដែលគាត់ទើបតែច្រូត ដើម្បីយកមកចិញ្ចឹមកូនប្រពន្ធ ដើម្បីឲ្យបានពីរ ឬបីខែសិនទំរាំគាត់ទៅភ្នំពេញ ឬទីរួមខេត្តផ្សេងទៀត ទៅស៊ីឈ្នួលគេ ជាគូលី លីសែង ជាអ្នកជាក់ស៊ីក្លូ ឬជាជាងសំណង់ បានលុយផ្ញើមកជូនគ្រួសារ ដើម្បីទិញអង្ករហូបតទៅទៀត។ ប៉ុន្តែដោយគាត់ត្រូវខ្ចីស្រូវគេតាំងពីពេលច្រូតកាត់ទៅហើយ ដល់ពេលច្រូតកាត់ក្រោយ គាត់ក៏ត្រូវសងគេទៀតទាំងដើមទាំងការ ដែលជាហេតុនាំឲ្យពីមួយឆ្នាំទៅមួយឆ្នាំ គាត់ក៏ត្រូវធ្លាក់ជ្រៅទៅៗ ជំពាក់គេរណ្ដែកដោយគ្មានសង្ឃឹមអ្វីថា នឹងត្រូវចេញរួចទេ។ នេះហើយដែលជាហេតុនាំឲ្យទាសភាពនៅមានរហូតដល់សព្វថ្ងៃ។ ឯគ្រួសារកសិករផ្សេងទៀតដែលមានភ័ពសំណាងជាងនេះ អាចនៅសល់ស្រូវសម្រាប់ហូបបាន៣ខែ ៤ខែ ៥ខែតែប៉ុណ្ណោះ។ ឯនៅមានការខ្វះខាតក៏ត្រូវទៅខ្ចីបុលគេទៀតដើម្បីបង្គ្រប់។ អ្នកខ្លះខ្វះស្រូវហូបតែ៣ ឬ៤ខែ អាច

[១៤៣] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៧៧-២៧៨



ជៀសវាងមិនទៅខ្ចីបុលគេបាន ដោយនាំគ្នាប្ដីប្រពន្ធធ្វើស្កថ្នោតលក់។ ប្ដីឡើងត្នោត ប្រពន្ធរំងាស់ស្ក។ ទោះបីយ៉ាងណាក៏ដោយ ជាទូទៅនៅជនបទកម្ពុជា កសិករមិនមែនជាអ្នកលក់អង្ករទេ ការតម្លើងថ្លៃអង្ករ ទោះបីជាតម្លើងថ្លៃនៅពេលណាក៏ដោយ គឺមានន័យថា ធ្វើឲ្យកសិករដែលត្រូវទៅទិញអង្ករកាន់តែថ្លៃថែមទៀត ដើម្បីយកមកហូប។ យល់សភាពការណ៍នេះនាំឲ្យយើងកាន់តែយល់អំពីទិសដៅនៃ "គណៈកម្មាធិការសកម្មភាព" ដែល លោកលន់ នល់ បានចាត់តាំងឡើងតាំងពីច្រើនឆ្នាំមកហើយ ហើយទើបតែមកទូលសម្ដេចនៅឆ្នាំ ១៩៦៧ នោះ។ ឥឡូវនេះ ឈរលើអ្វីដែលលោក បែន គៀរណាន់ ទើបតែសរសេរនេះ ក៏យើងអាចយល់ថា "នាយទុន" ដែលមាននិយាយនៅក្នុងអត្ថបទនេះ បានរកស៊ីជាមួយ លន់ នល់ តាំងពីយូរណាស់មកហើយ។ គឺ "នាយទុន" ទាំងនោះហើយ ដែលសកម្មជាងគេខាងលួចរូបីយប័ណ្ណជាតិយកទៅលក់នៅផ្សារងងឹត ដូចខ្ញុំបានសរសេរក្នុងសៀវភៅរបស់ខ្ញុំ។[១៤៤] កាលពីឆ្នាំ ១៩៦៣-១៩៦៦ គឺជាមួយនាយទុនទាំងអស់នេះហើយ ដែលលោកលន់ នល់រួមជាមួយដើម្បីបំផ្លាញការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីឆ្នាំ១៩៦៣។ បញ្ជី៣៤នាក់ ដែលលន់ នល់បានរៀបចំធ្វើ ហើយថ្វាយទៅសម្ដេចនៅឆ្នាំ១៩៦៣ ដោយមានបញ្ចូលឈ្មោះអ្នកសេដ្ឋកិច្ចខាងឆ្វេង ដូចជា ហ៊ូ យន់ ហ៊ុយ នឹម និងខ្លួនខ្ញុំ ក៏សំដៅទិសដៅបំផ្លាញការកែទម្រង់ខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះផងដែរ។ នៅឆ្នាំ១៩៦៥-១៩៦៦ ក៏ លោក លន់ នល់ រួមជាមួយ "នាយទុន" ទាំងអស់នោះដែរ ដើម្បីឆ្លៀតឱកាសពីការដឹកអាវុធពីកំពង់ផែព្រះសីហនុទៅឲ្យវៀតកុងនៅតាមព្រំដែន ដើម្បីដឹកអង្កររត់គយតាមឡានយោធា។[១៤៥] នេះហើយដែលជាការចំអកនៃប្រវត្តិសាស្ត្រ គឺរដ្ឋមន្ត្រីការពារប្រទេសរបស់

[១៤៤] ខៀវ សំផន "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ទំព័រ១២

[១៤៥] វីលីយ៉ាំ ហ្សូវគ្រូស "ទុក្ខសោកវេទនាមួយដែលគ្មាននរណាគិតគូរដល់" ទំព័រ៥៨

សម្តេច ជាអ្នករត់គយធ្វើឲ្យ "រដ្ឋសីហនុ "បាត់បង់ថវិកា ២ភាគ៣ ហើយរុញច្រានរដ្ឋនេះទៅដល់មាត់ច្រាំងនៃការរលំរលាយ។ ឥឡូវលោកលន់ នល់ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៃ "រដ្ឋភិបាលស្រោចស្រង់ និងសង្គ្រោះជាតិ" ដែលមានអំណាចធ្វើអ្វីក៏បាន ដើម្បីប្រោះព្រំសេដ្ឋកិច្ចឡើងវិញ។ មុននេះបន្តិច ក្រោយពីត្រូវបានតែងតាំងដោយសភា ដែលចេញមកពីការបោះឆ្នោតហើយភ្លាម លោកក៏គិតគូរ "បំបាត់" ការរត់គយភ្លាមដែរ! លទ្ធផលគឺកសិករនៅសំឡូតបះបោរ។ កសិករនៅសំឡូតបះបោរ ក៏លោកលន់ នល់បានជាឱកាសដេញកាត់ក កសិករ និង ពួកកុម្មុយនីស្ត ដែលលោកលន់ នល់អះអាងថា មានពួកវៀតកុង វៀតណាមខាងជើងជាអ្នកញាក់ខ្សែពីក្រោយ។

ការពិត វៀតណាមព្រួយបារម្ភខ្លាំងណាស់ ពីការដែលរបបរបស់សម្តេចត្រូវបានរង្គោះរង្គើខ្លាំងយ៉ាងនេះ ហើយអ្វីដែលនៅសល់បន្តិចបន្តួចពីនយោបាយអព្យាក្រឹត្យរបស់សម្តេចមានតម្លៃខ្លាំងណាស់ចំពោះគេ ក្រោយដែលគេទើបតែបាត់បង់ និងខូចខាតជាទម្ងន់នៅក្នុងការវាយសំរុកនៅក្នុងពេលចូលឆ្នាំថ្មីៗនេះ។[១៨៦]

ឯខាងផ្នែកពួកតស៊ូខ្មែរវិញ បញ្ហាដែលចោទ គឺបញ្ហាខ្វះអាវុធ និងគ្រាប់រំសេវយ៉ាងខ្លាំង។ នៅខែវិច្ឆិកាឆ្នាំ១៩៦៩ លោកសាឡុតស ដោយមានលោកស្រ្តី ខៀវ ប៉ុណ្ណារី អ្នកជំនួយការរបស់គាត់ឈ្មោះប៉ង និងអ្នកការពារគាត់ពីរនាក់ទៀត ចាកចេញម្តងទៀត ដោយដើរតាមផ្លូវលំហូជីមិញ។[១៨៧] លោកសង្ឃឹមទៅពន្យល់លោកឡៃ យន់ថា ដោយពេលនេះសម្តេចបានក្លាយជាឧបករណ៍របស់លន់ នល់ ទៅហើយ ពេលវេលាមកដល់ហើយ ដែលត្រូវជួយខាងអ្នកតស៊ូវិញ។

[១៨៦] បែន គៀរណាន់ "តើ ប៉ុល ពត ឡើងមកកាន់អំណាចតាមវិធីណា?" ទំព័រ២៧៥

[១៨៧] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៨៨



ប៉ុន្តែលោក សាឡុតស បានជ្រើសរើសពេលវេលាខុស។ ២ខែមុននេះ សម្តេចបានយាងទៅ ហាណូយ ដើម្បីចូលរួមបុណ្យសពលោកហូជីមិញ ហើយបានព្រមានអ្នកដឹកនាំវៀតណាមយ៉ាងច្បាស់ថា បើគេទាំងឡាយចង់ឲ្យកម្ពុជានៅជាអព្យាក្រឹត្យ ហើយបើកចំហដល់ការដឹកជញ្ជូនអាវុធ និងគ្រាប់រំសេវដល់ពួកវៀតកុង គេទាំងឡាយត្រូវបង្ហាញនូវការគាំទ្ររបស់គេចំពោះសម្តេច។

ដូច្នេះនៅពេលនោះ ចំពោះលោក ឡៃ យន់ លោកសាឡុតស ជាមនុស្សម្នាក់ដែលរំខានគាត់ខ្លាំងណាស់។ លោក ទទូចសុំឲ្យលោកសាឡុតស បញ្ឈប់ការបះបោរ ហើយត្រឡប់មកតស៊ូនយោបាយវិញ។ ថ្ងៃក្រោយមក លោកសាឡុតសសរសេរថា ការសន្ទនាបានប្រព្រឹត្តទៅក្នុងបរិយាកាសតឹងតែងខ្លាំងណាស់។[១៨៨] ទំនាស់រវាងយើងទាំងពីរ "គ្មានអ្វីតភ្ជាប់គ្នាវិញបានទេ"។ ហើយលោកបន្ថែមទៀតថា "ប្រតិភូវៀតណាម... មិនអាចទប់ការខឹងសម្បារ... នឹងការច្រឡោតតោតតូងរបស់គេបានទេ។ បរិយាកាស... តឹងតែងខ្លាំងរហូតដល់ សមាជិកគណៈប្រតិភូខ្មែរខ្លះ ដែលមិនធ្លាប់ជួបប្រទះនឹងរឿងរ៉ាវរបៀបនេះ ត្រូវរង្គោះរង្គើខ្លាំងមែនទែន។ ពេលមានប្រសាសន៍យ៉ាងនេះ គឺលោក សាឡុតស ចង្អុលទៅជម្ងឺរបស់លោកស្រ្តី ខៀវប៉ុណ្ណារី ជាប្រពន្ធគាត់ដែល នឹងលេចចេញនៅពេលដែលប្រតិភូខ្មែរទៅដល់ប៉េកាំង។ លោកស្រី ប៉ុណ្ណារី ចាប់ផ្តើមមានអកប្បកិរិយាមិនធម្មតា។ អ្នកផ្ទះការចិនម្នាក់ដែលបានជួបលោកស្រី ខៀវ ប៉ុណ្ណារី ពេលនោះ បាននឹកឃើញពីគាត់ថា "គាត់ប្រឆាំងនឹងវៀតណាមរហូតដល់អ្នកណានិយាយពាក្យ "វៀតណាម" នៅមុខគាត់មិនបានទាល់តែសោះ"។ មន្ត្រីចិននោះចោទសួរខ្លួនឯងថា អ្វីទៅដែលបានធ្វើឲ្យគាត់ទៅជាយ៉ាងនេះ។[១៨៩] ចាប់តាំងពីថ្ងៃដែលគណៈប្រតិភូ

[១៨៨] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ១៨៨ (អ្នកនិពន្ធយោងទៅសៀវភៅខ្មៅ ទំព័រ៣២)

[១៨៩] ហ្វីលិព ហ្សូត "ប៉ុល ពត..." ទំព័រ២១០

ទៅដល់ប៉េកាំង គាត់ចាប់ផ្ដើមឈឺ រហូតដល់គេត្រូវសែងគាត់ដាក់លើស្នែង។ យូរក្រោយមកទៀតហើយ ទើបគេរកឃើញថា ជម្ងឺគាត់ជាជម្ងឺសរសៃប្រសាទម្យ៉ាងដែលនាំឲ្យចេះតែភ័យខ្លាច។ ពេលនោះជាការហួសពេលទៅហើយ ដើម្បពិនិត្យ និងព្យាបាលគាត់។ អ្នកជាំបាយឲ្យលោកសាឡុតស ឈ្មោះ មឿន បាននឹកឃើញថា ថ្ងៃមួយអ្នកការពាររបស់គាត់បានដាក់ទឹកមួយកែវជូនលោកសាឡុតស។ "ពេលនោះប្រពន្ធគាត់សម្លឹងទៅគាត់ហាក់ដូចជាចង់និយាយថា កុំឲ្យគាត់ហូបទឹកនោះ ពីព្រោះយួនបានដាក់ថ្នាំពុល រួចគាត់ងើបទៅយកកែវទឹកនោះទៅចាក់ចោល ហើយគាត់ដាក់កែវទឹកមួយទៀតជំនួស"។ មឿន និយាយថា គាត់បានសង្កេតឃើញទឹកមុខអាណិតអាសូររបស់លោកសាឡុតស។ ក្រោយពីវិបត្តិបានកន្លងផុតទៅគាត់ ហាក់ដូចជាបានជាសះស្បើយវិញ ហើយមានអកប្បកិរិយាធម្មតាវិញ ប៉ុន្តែជាញឹកញាប់ គាត់ធ្លាក់ក្នុងវិបត្តិឡើងវិញ ហើយគាត់ចេះតែភ័យខ្លាចសំរាកមិនលក់។ គាត់ចេះតែ "ស្រែកថា កងទ័ពវៀតណាមមកហើយ! វាមករកសម្លាប់យើង!"។ នៅទីបញ្ចប់លោកសាឡុតស ដែលខ្លួនលោក៏សំរាកមិនសូវបានផងដែរ ក៏បញ្ជូនប្រពន្ធគាត់ឲ្យទៅនៅជាមួយលោកស្រីមឿន ពេលណាគាត់មានវិបត្តិ ដើម្បីកុំឲ្យគាត់ពិបាកសំរាកមិនបានដោយប្រពន្ធគាត់ចេះតែស្រែកភ័យអំពីសត្រូវដែលប្រពន្ធគាត់ចេះតែឃើញយ៉ាងនេះ។

គេមិនដែលរកឃើញបានច្បាស់ អំពីមូលហេតុនៃជម្ងឺរបស់ប្រពន្ធគាត់ទេ។ ចំពោះមិត្តភ័ក្តជិតស្និទគេគិតថា មកពីគាត់គ្មានកូន ហើយគេនឹកឃើញថា ពេលគាត់ជិតស្លាប់ទៅគាត់ចូលចិត្តឲ្យក្មេងៗទៅជុំវិញគាត់ ហើយការមានក្មេងៗនៅជុំវិញគាត់ បានជួយឲ្យគាត់មានអកប្បកិរិយាធម្មតាឡើងវិញ។ គាត់ដឹងថា លោកសាឡុតសចង់បានកូន ប៉ុន្តែប្ដីគាត់មិនដែលនិយាយចេញស្ដីអ្វីទេ។

ប៉ុន្តែអ្វីដែលនាំឲ្យគាត់កើតមានវិបត្តិ គឺនៅពេលដែលគាត់ និងគណៈប្រតិភូស្នាក់នៅចិន គឺនៅពេលថ្មីៗនេះ។ ជម្ងឺរបស់គាត់អត់មានអ្វីទាក់ទងនឹងសាឡុតសទេ ហើយក៏រឹតតែគ្មានអ្វីទាក់ទងទៅនឹងនយោបាយរបស់ខ្មែរក្រហមទៅទៀត ពីព្រោះនយោបាយនោះមិនទាន់ទាំងបានសរសេរលើក្រដាស់នៅឡើយទេ ហើយក៏មិនទាន់បានអនុវត្តផងដែរ នៅពេលដែលគាត់ចាប់ផ្ដើមរង្គោះរង្គើ។ ការពិតទៅជម្ងឺដ៏គួរឲ្យអាណោចអាធម៌របស់គាត់នេះ អាចនិយាយបានថាជាការប្រមូលផ្ដុំនៃការព្រួយបារម្ភណ៍របស់ជាតិខ្មែរទាំងមូល ចំពោះគ្រោះថ្នាក់មួយ ដែលនៅរង់ចាំនៅពីខាងមុខប្រទេសទាំងមូល។

នៅក្នុងពេលដដែលនេះ នៅភ្នំពេញ សម្ដេចក៏មិនអាចរើព្រះអង្គរួចចេញឲ្យផុតពីសភាពការណ៍ដែលសង្កត់លោកកាន់តែធ្ងន់ឡើង។ ប៉ុន្មានខែមុននេះ កាលពីព្រះអង្គយាងទៅចូលរួមបុណ្យសពហូជីមិញ ព្រះអង្គបានខិតខំពន្យល់ហាណូយកុំឲ្យបញ្ចោញកម្លាំងរបស់គេ ឲ្យគេឃើញខ្លាំងពេក ប៉ុន្តែក៏មិនបានផល។ ឥឡូវនេះដល់ពេល ដែលព្រះអង្គត្រូវចេញពីពេទ្យ ព្រះអង្គគិតថា នឹងត្រឡប់ចូលប្រទេសវិញតាមមូស្គូ និងប៉េកាំង ដើម្បីសុំឲ្យអ្នកដឹកនាំសហភាពសូវៀត និងចិន ប្រើឥទ្ធិពលរបស់គេទៅសង្កត់លើអ្នកដែលនៅក្រោមអាណាព្យាបាលរបស់គេឲ្យនៅឲ្យស្ងាត់បន្តិច។ ដើម្បីឲ្យមានទម្ងន់ដល់ពាក្យដែលព្រះអង្គបំរុងនឹងនិយាយនៅម៉ូស្គូ និងប៉េកាំងនោះ ព្រះអង្គក៏សុំឲ្យលន់ នល់រៀបចំ "បាតុកម្ម ដែលបានកើតមានឡើងដោយឯកឯង" ប្រឆាំងនឹងវៀតណាមមុននឹងលោកយាងទៅដល់ម៉ូស្គូ និងប៉េកាំង ១ថ្ងៃ ២ថ្ងៃ។[១៥០]

ថ្ងៃ៨ មីនា បាតុកម្មប្រឆាំងវៀតកុងបានផ្ទុះឡើងនៅស្វាយរៀង និងនៅច្រើនស្រុកនៃខេត្តនេះថែមទៀត។ ស្អែកឡើងនៅភ្នំពេញនិសិត្សក៏ធ្វើបាតុកម្មនៅមុខរដ្ឋសភា ហើយគេមានទាំងធ្វើញត្តិមួយទាមទារឲ្យវៀតកុងដកចេញពីទឹកដីខ្មែរ។ ពីរថ្ងៃក្រោយមកទៀត គឺថ្ងៃ១១ អ្នករាជការរាប់ម៉ឺននាក់ ដែលគេទុកពេលឲ្យដើម្បីទិសដៅនេះ ក៏នាំគ្នាដើរសំដៅទៅស្ថានទូតនៃរដ្ឋាភិបាល

[១៥០] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៩៤

បដិវត្តន៍បណ្ដោះអាសន្ននៃវៀតណាមខាងត្បូង។ ទោះបីមានប៉ូលីសនៅទីនោះក៏ដោយ ហ្វូងមហាជនដែលភ្ញាក់ផ្អើលរដ្ឋាភិបាលជំរុញពីក្រោយក៏រុញច្រានទ្បានទូតឲ្យបះកង់ឡើងលើ ហើយកងទ័ពដែលស្លៀកពាក់ស៊ីវិលក៏នាំគ្នាសំរុកទៅអាគារស្ថានទូត លើកតុ ទូសៀវភៅ និងក្រដាសបោះចេញតាមបង្អួចពីជាន់ខាងលើ ហើយក៏ដុតចោល។[១៥១] ក្រោយពីបាននៅទីនោះប្រហែលមួយម៉ោងដើម្បីប្លន់ ហ្វូងមនុស្សក៏ដើរសំដៅទៅស្ថានទូតវៀតណាមខាងជើង។ នៅទីនោះអ្វីៗក៏ត្រូវកំទេចទាំងអស់។ ការបះបោរក៏បន្តមានឯនេះបន្តិច ឯនោះបន្តិច ហើយហាងលក់ទំនិញ និងផ្ទះឯកជនខ្លះក៏ត្រូវគេវាយកំទេច។[១៥២]

គេពិបាកនិយាយណាស់ តើការឈានរហូតទៅដល់វាយកំទេចស្ថានទូតជាចេតនារបស់សម្ដេចឬយ៉ាងណា ហើយក៏គេពីបាកនិយាយដែរ តើលន់ នល់ និងសិរិមតៈ សង្ឃឹមថា បរិយាកាសហឹង្សាដែលកំហឹងរបស់មហាជនបានបង្កើតឡើងប្រឆាំងនឹង "សត្រូវស្លូតូជ" និងបង្កើតលក្ខខ័ណ្ឌនយោបាយជាចាំបាច់ដើម្បីគេបន្តសកម្មភាពរបស់គេឲ្យកាន់តែខ្លាំងថែមទៀត ឬយ៉ាងណា។

អ្វីដែលច្បាស់ គឺសម្ដេចព្រមាន " ឥស្សរៈជនដែលមានបំណងបំផ្លាញមិត្តភាពរបស់កម្ពុជាជាមួយប្លុកសង្គមនិយមឲ្យកែលៃងបាន" ហើយលោកមានបន្ទូលថា ពេលណាលោកយាងមកដល់ប្រទេសវិញ លោកនឹងសុំឲ្យប្រជាជនខ្មែរជ្រើសរើស រវាងលោក និងអ្នកទាំងនោះ។[១៥៣]

ថ្ងៃ១៣ មីនា ក្រោយពីមានការស្ទាក់ស្ទើរច្រើន សម្ដេចក៏យាងឡើងយន្តហោះពីប៉ារីសទៅម៉ូស្គូ។ ថ្ងៃ១៨ មីនា សម្ដេចត្រូវរដ្ឋសភាទម្លាក់។ សម្ដេច

[១៥១] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៨៨

[១៥២] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ២០១

[១៥៣] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៩៩



ជ្រាបពីរឿងនេះនៅម៉ូស្គូ ដោយលោកនាយករដ្ឋមន្ត្រីកូស៊ីហ្គីន ពេលដែលលោកជូន ដំណើរព្រះអង្គឡើងយន្តហោះដើម្បីយាងទៅប៉េកាំង។

មិនមែនជាលើកទីមួយទេ ដែលសហភាពសូវៀតទទួលប្រមុខរដ្ឋបរទេសពីតតីយលោក ហើយស្រាប់តែត្រូវគេដកយកប្រទេសចេញពីខ្លួនបាត់ ហើយលោកកូស៊ីហ្គីនក៏ត្រូវជំរាបគេវិញថា សហភាពសូវៀតមិនដឹងធ្វើម៉េចកើតទេ។

ឯចិនវិញមានប្រតិកម្មខុសពីនេះ។ តាំងពីឆ្នាំ១៩៦៥មក ចិនសម្លឹងមើលវៀតណាមតាមរយៈកែវឆ្លុះនៃទំនាស់ចិន និងសូវៀត។ ប៉េកាំងជាប្រកពជំជាងគេនៅឡើយខាងផ្នែកផ្ដល់ជំនួយយោធា ហើយបានខំអស់លទ្ធភាពខ្លួនដើម្បីរក្សាវៀតណាមឲ្យនៅខាងគេ។ ព្រឹកឡើងពេលដែលយន្តហោះចុះនៅប៉េកាំង សម្ដេចទតឃើញអង្គទូតទាំងមូលនៅឈរតំរៀបគ្នានៅចាំគោរពព្រះអង្គ។ លោកជូអេងឡាយក៏លោកអញ្ជើញទៅដែរ។ នៅក្នុងឡាននៅតាមផ្លូវ លោកនាយករដ្ឋមន្ត្រីចិនក៏សួរមតិសម្ដេច សម្ដេចឆ្លើយតបភ្លាមថា "ខ្ញុំនឹងត្រឡប់ទៅក្នុងប្រទេសវិញ ដើម្បីប្រយុទ្ធ"។ ជូ អេងឡាយ ក៏ព្រមានលោកវិញថា "សង្គ្រាម គឺយូរអង្វែង លំបាកវេទនា គ្រោះថ្នាក់ ហើយពេលខ្លះធ្វើឲ្យអស់សង្ឃឹមទៀត" ហើយក៏ស្នើទៅលោកវិញថា សូមលោកទុកពេលមួយថ្ងៃដើម្បីគិតថែមទៀត។[១៥៤]

ការពិត សម្ដេចមិនទាន់ច្បាស់ក្នុងប្រទ័យរបស់ព្រះអង្គនៅឡើយទេ អំពីថាលោកត្រូវធ្វើអ្វីនោះ។ នៅលើយន្តហោះ ព្រះអង្គបាននិយាយជាមួយព្រះមហេសីមូនិច ចង់យាងទៅគង់នៅក្នុងវិឡារបស់ព្រះអង្គនៅមូហ្សាំងនៅមាត់សមុទ្រខាងត្បូងស្រុកបារាំង។ ប្រតិកម្មដំបូងរបស់លោក ពេលលោកយាងមកដល់ គឺទៅសាកសួរទូតបារាំងនៅចិន ឈ្មោះអេដែន ម៉ាណាក់ អំពីលទ្ធភាពថ្វាយសិទ្ធិលោកជ្រកកោន។ ពីមុនៗមកធ្លាប់មានករណីប្រហាក់ប្រហែលគ្នានេះរួចហើយ គឺព្រះចៅអធិរាជវៀតណាមឈ្មោះ បាវ ដាយ

[១៥៤] ហ្វីលិព ហ្សុត "ប៉ុល ពត..." ទំព័រ១៩៨

ដែលបានបញ្ចប់ជីវិតរបស់លោកនៅវីវៀរ៉ា។ ដូចគ្នានេះដែរក៏មានស្តេចហ្វារុកនៃប្រទេសអេស៊ីប។ ប៉ុន្តែសម្តេចមិនចូលចិត្តពួកនេះទេ។[១៩៥]

ស្អែកឡើង សម្តេចបានជំរាបលោកជូ អេងឡាយ ថា លោកបានសម្រេចចិត្តហើយ។ ក្នុងសា T មួយទៅប្រជាជនកម្ពុជាក្នុងវិទ្យុប៉េកាំង សម្តេច និងបរិហាពួកធ្វើរដ្ឋប្រហារ ហើយលោកនឹងប្រយុទ្ធដើម្បី "យុត្តិធម៌" គឺមានន័យថា ដើម្បី "សងសឹក"។

ថ្ងៃ២១មីនា នាយករដ្ឋមន្ត្រីវៀតណាម ផាំវ៉ាន់ដុង ក៏ជិះយន្តហោះមកប៉េកាំងដែរ លោកសួរសម្តេចថាតើចង់សហការណ៍ជាមួយខ្មែរក្រហមឬទេ? ហើយក៏បន្ថែមទៀតថា បើលោកចង់នឹងមានការទាក់ទងគ្នាទាំងជាមួយថ្នាក់ដឹកនាំ ទាំងថ្នាក់ផ្សេងទៀត។[១៩៦] លោកនាយករដ្ឋមន្ត្រីវៀតណាមជំរាបលោកជូ អេងឡាយថា "សម្តេចមិនមានបន្ទូលអ្វីទាំងអស់ ក្រៅពីនិយាយជារួមថាសុខចិត្តតស៊ូ សម្តេចមិននិយាយថា ចង់ឲ្យយើងធ្វើអ្វីក៏លោកមិននិយាយ"។ អ្នកដឹកនាំវៀតណាមក៏ជួបលោកសាឡុតសដែរ ពេលនេះលោកសាឡុតសឃើញថា ទឹកមុខរបស់គេខុសប្លែកកាលពីពីរខែដែលជួបគ្នាមុនៗ ឥឡូវនេះអ្វីៗក៏ "មិត្តភាព និងសាមគ្គីភាព (ហើយមានតែពាក្យមិត្តភាព និងការឱបរឹតគ្នា...)។ គឺជាការផ្លាស់ប្តូរ១៨០អង្សា"។[១៩៧] សម្ព័ន្ធភាពរវាងសម្តេចនរោត្តម សីហនុ និងពួកកុម្មុយនីស្តខ្មែរប្រែទៅជាផលប្រយោជន៍សម្រាប់ទាំងអស់គ្នា។ ហើយផាំ វ៉ាន់ដុង ក៏សន្យាជាមួយសម្តេចយ៉ាងច្បាស់លាស់ដោយ "សុខចិត្តស្បថ" នៅចំពោះមុខលោក ជូ អេងឡាយថា វៀតណាម និងគោរព " ឯករាជភាព អធិបតេយ្យភាព និង បូរណភាពទឹកដី" របស់កម្ពុជា "នៅក្នុងព្រំដែនបច្ចុប្បន្ន"។[១៩៨]

[១៩៥] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៩៨

[១៩៦] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៩៨

[១៩៧] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៩៩

[១៩៨] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ១៩៩



តែនៅពេលនោះ គ្មានអ្នកដឹកនាំវៀតណាមណាម្នាក់ ចោទសួរខ្លួនឯងថា បើប្រសិនជាលោក សាឡុតស ធ្វើតាមការសង្កត់របស់លោក ឡេ យន់ កាលពីខែមុននោះឱ្យឈប់តស៊ូអាវុធនោះ តើសភាពការណ៍វានឹងទៅជាយ៉ាងណាទៅវិញ។ គេជាប្រទេសធំគេមិនចេះខុសទេ។

២ថ្ងៃក្រោយមក គឺថ្ងៃ២៣ មីនា សម្តេចក៏ផ្សាយសេចក្តីអំពាវនាវដែលទាំងអស់គ្នាដឹងអស់ហើយ។ សម្តេចបានជូនគំរោងដំបូងទៅលោកជូ អេងឡាយ ហើយលោកជូ អេងឡាយ ក៏បានជូនទៅលោកសាឡុតស ហើយលោកសាឡុតស ក៏បានស្នើកែសំរួលបន្តិចបន្តួច ពិសេសគឺលុបចំណុចដែលទាក់ទងនឹងអ្វីដែលនិយាយដល់សង្គមនិយម។ លោកនាយករដ្ឋមន្ត្រីចិន ក៏ជំរាបលោកសាឡុតសថា "ពួកកុម្មុយនីស្តខ្មែរត្រូវគិតគូរដល់សភាពការណ៍ទូទៅនៅក្នុងប្រទេស ហើយមិនត្រូវគិតដល់ទំនាស់ចាស់ទៀតទេ... អស់អ្នកត្រូវសហការណ៍គ្នា ដើម្បីរៀបចំរដ្ឋាភិបាលរួមគ្នាមួយប្រឆាំង និងសត្រូវរួម"។ លោកសាឡុតស មិនចាំបាច់គេនិយាយពន្យល់អ្វីទេ។ ប៉ុន្តែលោកមិនអញ្ជើញទៅជួបសម្តេចដូចលោកជូ អេងឡាយស្មាននោះទេ លោកបែរជាសរសេរសំបុត្រគាំទ្រក្នុងនាមខៀវ សំផន ហ៊ូ យន់ ហ៊ុយ នឹម ដែលខ្មែរភាគច្រើនស្មានថាស្លាប់អស់ទៅហើយ តាមបញ្ជារបស់សម្តេចកាលពី៣ឆ្នាំមុនៗ សំបុត្រក៏បានប្រគល់ថ្វាយសម្តេចនៅថ្ងៃ២៦មីនា ដូចជាគេបានផ្ញើមកពីមូលដ្ឋានមួយនៃការតស៊ូពីក្នុងប្រទេស។ គ្មានអ្នកណាទូលសម្តេចថា លោកសាឡុតស នៅប៉េកាំងដែរកាលពីពេលនោះទេ។ ដើមខែមេសា ១៩៧០ លោកសាឡុតសក៏ត្រឡប់មកហាណូយវិញ។ នៅពេលនោះលោក និងលោកស្រី ខៀវ ប៉ុណ្ណារីត្រូវបានទទួលដោយអឹកធឹកពីលោកឡេ យន់, ផាំ វ៉ាន់ដុង, វ៉ងៀនយ៉ាប់ ហើយនិងសមាជិកផ្សេងទៀត នៃការិយាល័យនយោបាយនៃបក្សពលករវៀតណាម។ មុននឹងអស់លោកត្រឡប់ទៅតាមផ្លូវលំហូជីមិញវិញ ដើម្បីត្រឡប់ទៅស្រុក លោក ឡេ យន់ សុំជួបលោកសាឡុតស ដើម្បីជជែកពីកិច្ចសហការខាងយោធា។[១៩៩]

[១៩៩] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ២០៣

ពេលដែលលោកសាឡុតសមិននៅ លោកនួន ជា -នៅថ្ងៃដែលផ្ទុះរដ្ឋប្រហារនៅជាមួយលោកសូ ភឹមនៅក្របៅកំពុងតែប្រជុំជាមួយកម្មាភិបាលខាងភូមិភាគបូព៌ា ហើយបានណែនាំឲ្យក្រុមឃោសនាប្រដាប់អាវុធឲ្យកាន់កាប់ភូមិ ឃុំ និងស្រុក នៅគ្រប់កន្លែងដែលអាចធ្វើទៅបាន។ មួយអាទិត្យក្រោយ ពីការផ្សាយសេចក្ដីអំពាវនាវរបស់សម្ដេច មន្ត្រីផ្លូវការរបស់វៀតណាមបានទៅជួបគាត់ ដើម្បីស្នើសហការគ្នាខាងយោធា។ មុនដំបូងលោក នួន ជា មានការរាវែក។ ប៉ុន្ដែដល់ពេលដែលវៀតណាមគូសសង្កត់ថា ទោះបីជាខ្មែរយល់យ៉ាងណាក៏ដោយ គេត្រូវតែការពារកន្លែងដែលគេជ្រកនៅ នៅស្រុកខ្មែរហើយនួន ជាក៏ទទួលគោលការណ៍សហការគ្នាវិញ ប៉ុន្ដែគាត់មិនទាន់ចូលនិយាយល្អិតទេ ផ្ទុយទៅវិញគាត់ផ្ញើសំបុត្រមួយមកលោកសាឡុតសនៅហាណូយ រៀបរាប់អំពីគេស្នើយ៉ាងម៉េចហើយគាត់បានតបទៅគេវិញយ៉ាងម៉េច។ ឥឡូវនេះឡៃ យន់ ចង់ដឹងថា តើ ស មានមតិយ៉ាងណា។[១៦០]

តាមលោកសាឡុតស និយាយការចរចាគ្នាមានការលំបាក។ វៀតណាមចាប់ផ្ដើមស្នើជូនកាំភ្លើង៥០០០ដើម ដើម្បីបំពាក់ឲ្យអង្គភាពខ្មែរក្រហម។ ខ្មែរក៏យល់ស្របទទួល ប៉ុន្ដែឡៃ យន់ក៏ស្នើទៀតថា ឲ្យចាត់តាំងបញ្ជាការរួមជាមួយគ្នា។ ចំពោះលោកសាឡុតស ការស្នើនេះធ្វើឲ្យគាត់នឹកឃើញដល់ ជំនាន់ឆ្នាំ១៩៥០ ដែលខ្មែរជា "បញ្ជាការ" ប៉ុន្ដែវៀតណាមដែលជា "អនុបញ្ជាការ" ជាអ្នកសម្រេចលើអ្វីៗទាំងអស់។ គាត់នឹកឃើញថា ខ្មែរនឹងធ្លាក់ខ្លួនទៅនៅក្រោមអណាព្យាបាលវៀតណាមទៀតហើយ។ លោកសាឡុតសក៏យកលេសថា ពេលដែលគាត់ចេញមកពីក្នុងប្រទេស គាត់គ្មានអាណត្តិពីគណៈកម្មាធិការកណ្ដាលរបស់បក្សកុម្មុយនីស្ដកម្ពុជា ដើម្បីជជែកពីបញ្ហានេះទេ។ ប៉ុន្ដែជាមតិផ្ទាល់ខ្លួនគាត់ "គាត់យល់ថាចាត់តាំងបញ្ជាការរួមមិនចំណេញទេ។ ពិសោធន៍កន្លងមកបានបង្ហាញថា បញ្ជាការរួមជាប្រភពនាំឲ្យឈ្លោះប្រកែក

[១៦០] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ២០៣



គ្នា។ ហើយខាងនយោបាយវិញ បញ្ជាការរួមនាំឲ្យអ្នកផងមើលទៅថា ចលនាតស៊ូរបស់ខ្មែរណែបវៀតណាម ហើយសម្ដេចក្ដី ប្រជាជនខ្មែរក្ដី មិនទទួលទេ។ ឡៃ យន់ធ្វើហាក់ដូចជាយល់។[១៦១]

ប៉ុន្ដែនៅមានបញ្ហាជាមូលដ្ឋានជាច្រើនផ្សេងៗទៀត ដែលដោះស្រាយមិនទាន់បាន។ ឧទាហរណ៍ចំពោះអ្នកដឹកនាំបក្សកុម្មុយនីស្ដកម្ពុជា កម្ពុជានិងវៀតណាមជាប្រទេស២ ជាតិ២ និងប្រជាជន២។ ច្បាស់ហើយថា នៅក្នុងការតស៊ូប្រឆាំងនឹងសត្រូវរួម គេទាំងឡាយត្រូវតែសាមគ្គីគ្នា និងជួយគ្នាទៅវិញទៅមក។ ប៉ុន្ដែដោយសារថា គេជាប្រទេស២ ជាតិ២ និងប្រជាជន២ ក៏ត្រូវមានបក្ស២ កងទ័ព២ រដ្ឋអំណាច២ អធិបតេយ្យ។ កម្លាំងប្រដាប់អាវុធវៀតណាមត្រូវទៅធ្វើសកម្មភាពនៅវៀតណាមខាងត្បូង ឯការតស៊ូរបស់ខ្មែរត្រូវទុកឲ្យខ្មែរប្រយុទ្ធនៅក្នុងក្របខណ្ឌអធិបតេយ្យភាពរបស់ខ្មែរ។ ដូចជាការជ្រើសរើសមនុស្សចូលកងទ័ព ឬចាត់តាំងកងទ័ព រួមទាំងការចាត់តាំងរដ្ឋអំណាចគ្រប់ថ្នាក់នៅស្រុកខ្មែរ ត្រូវនៅជាអធិបតេយ្យភាពរបស់ខ្មែរ។ គឺការដែលមិនគោរពគោលការណ៍ជាមូលដ្ឋានទាំងអស់នេះហើយ ដែលជាឫសគល់នាំឲ្យមានការប៉ះទង្គិចគ្នារវាងកម្លាំងទាំងពីរជាប់រហូតមក តាំងពីថ្ងៃដែលកម្លាំងវៀតណាមបុកចូលកម្ពុជាជាលើកដំបូងម្ល៉េះ។ ឯខាងវៀតណាមវិញ គេតែងតែលើកគោលការណ៍ផ្សេងពីនេះគឺថា "ឥណ្ឌូចិនជាសមរភូមិតែមួយ"។ ដូច្នេះហើយ ក្រោយរដ្ឋប្រហារសម្ព័ន្ធភាពរវាងសម្ដេចនរោត្តមសីហនុ និងពួកកុម្មុយនីស្ដខ្មែរមើលពីក្រៅទៅ ហាក់ដូចជា បានលុបបំបាត់ទំនាស់ដែលបានកើតមានរវាងបក្សទាំងពីរ អស់រយៈពេលជាង១៥ឆ្នាំមកហើយក៏ពិតមែន ប៉ុន្ដែទំនាស់រវាងបក្សទាំងពីរនៅជាមូលដ្ឋាន ពីព្រោះបញ្ហាដែលចោទ គឺបញ្ហានៃការទាក់ទងរវាងបក្សទាំងពីរ តើស្មើភាព ឬមិនស្មើភាព? គោរពអធិបតេយ្យគ្នាទៅវិញទៅមកឬមិនគោរព។ ប៉ុន្ដែតាំងពីពេលនេះទៅ

[១៦១] ហ្វីលិព ហ្សត "ប៉ុល ពត..." ទំព័រ២០៣

បក្សពលករវៀតណាមដឹងច្បាស់ហើយថា បក្សកុម្មុយនីស្តកម្ពុជាមិនចំណុះតាមខ្លួនងាយៗទេ។

ដូច្នេះហើយបានជាចាប់ពីពេលនេះទៅហើយ បក្សទាំងពីរទំនាស់គ្នាជាប់ ហើយគ្រាន់តែពេលខ្លះលេចចេញឲ្យអ្នកក្រៅមើលឃើញ ពេលខ្លះនៅកប់ៗ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទំនាស់នៅកប់តែប.ក.ក.ត្រូវប្រយុទ្ធប្រឆាំងអាមេរិក-លន់ នល់ផង ទប់ទល់មហិច្ឆិតាប្រទេសធំរបស់វៀតណាមផងៗ ដល់ឆ្នាំ១៩៧៣ទំនាស់ក៏លេចធ្លោទៀតៗ[១៦២] ឆ្នាំ១៩៧៦ វៀតណាមក៏សម្រេចបំបាត់ចោលសម្ព័ន្ធមិត្តដែលមិនជាទីគាប់ចិត្តនេះចោលតែម្តងៗ ប៉ុន្តែគ្មាននរណាយល់អំពីការសម្រេចនេះសោះ។

[១៦២] ខៀវ សំផន ៈប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់ៈ ទំព័រ៥៦